2021

神奈川県
教育委員会
KANAGAWA

| | |
|---|---|
| 学校 | |
| 名前 | |

２０２１年度入学希望者用
លកខណ្ឌសំរាប់សិស្សចូលរៀននៅឆ្នាំ 2021

神奈川県に住む日本語を母語としない方へのご案内
ការណែនាំសំរាប់ជនជាតិបរទេសរស់នៅក្នុងខេត្តកាណាហ្កាវ៉ាដែលភាសាជប៉ុនមិនមែនជាភាសាកំណើត

# 神奈川県の「公立高校入学のためのガイドブック」

日本語＋カンボジア語翻訳版
ភាសាជប៉ុន ＋ បកប្រែជាភាសាខ្មែរ

# 「សៀវភៅមគ្គុទ្ទេសន៍សំរាប់ការចូលរៀននៅមធ្យមសិក្សាកំរិតទី២ ខេត្តកាណាហ្គាវ៉ា」


神奈川県
教育委員会
令和3年度神奈川県公立高等学校入学者選抜
募集案内

このガイドブックは、神奈川県教育委員会が発行する「令和３年度神奈川県公立高等学校入学者選抜　募集案内」の内容をもとに作成されています。

សៀវភៅមគ្គុទេសន៍នេះ
គឺរៀបចំឡើងដោយគណកម្មាធិការក្រសួងអប់រំខេត្តកាណាហ្កាវ៉ាស្តីអំពី
(ឆ្នាំ2021ការផ្តល់ដំណឹងអំពីការប្រលងជ្រើសរើសសិស្សចូលរៀនវិទ្យាល័យរដ្ឋក្នុងខេត្តកាណាហ្គាវ៉ា)

作成：神奈川県教育委員会＋NPO法人多文化共生教育ネットワークかながわ（ME-net）
រៀបរៀងដោយៈ គណៈកម្មាធិការក្រសួងអប់រំខេត្តកាណាហ្កាវ៉ានិងបណ្តាញអង្គការពហុវប្បធម៌នឹងសិក្សាធិការ ប្រចាំខេត្តកាណាហ្កាវ៉ា

# មាតិកា

ចំណុចសំខាន់ៗ----មុនពេលប្រឡង

មើលទំព័រទី

1. ស្តីពីប្រភេទនៃវិទ្យាល័យ……1

（１） ភាពខុសគ្នារវាងវិទ្យាល័យរដ្ឋ និងវិទ្យាល័យឯកជន

（２） ភាពខុសគ្នារវាង ប្រភេទវិទ្យាល័យរៀនពេលថ្ងៃ ,រៀនពេលយប់ និង រៀនតាមប្រព័ន្ធប្រៃសណីយ៍

（３） ភាពខុសគ្នារវាងប្រព័ន្ធថ្នាក់និងប្រព័ន្ធពិន្ទុ

（４） ស្តីពីការរៀនមុខវិជ្ជាទូទៅ ,មុខវិជ្ជាបច្ចេកទេស និង មុខវិជ្ជាចំរុះ

សូមពិនិត្យសាឡើងវិញ ---- នៅពេលប្រឡង

2. គំរោងកម្មវិធី មុនពេល ប្រឡង……3

3. តារាង នៃកម្មវិធីការប្រឡងជ្រើសរើសសិស្សចូលវិទ្យាល័យរដ្ឋ……4

4. លក្ខណៈសម្បត្តិនិងឯកសារផ្សេងៗនៃការដាក់ពាក្យប្រឡង……5

（１） លក្ខណៈសម្បត្តិនៃការដាក់ពាក្យប្រឡង

（２） ឯកសារសំខាន់ផ្សេងៗសំរាប់ការដាក់ពាក្យប្រឡង

5. ប្រព័ន្ធប្រាក់ថ្លៃប្រឡងវិទ្យាល័យរដ្ឋ និង ការកាត់បន្ថយប្រាក់ថ្លៃចូលរៀន……6

6. លិខិតអង្កេតការសិក្សា……7

7. លិខិតសម្ភាសន៍……8

8. ការបំពេញឯកសារសំរាប់សិស្សបានបញ្ចប់ការអប់រំគ្រប់៩ឆ្នាំនៅឯបរទេស……9

9. ស្តីពីការប្រឡងជ្រើសរើសចូលវិទ្យាល័យរដ្ឋ……10

① ការប្រឡងជ្រើសរើសជាទូទៅឬករណីពិសេស

② ការជ្រើសរើស ជាពិសេសនូវជនបរទេសក្នុងខេត្តនិងសិស្សត្រូវបានត្រឡប់មកពីបរទេស

③ ការបែងចែកប្រឡងជ្រើសរើស（រៀនពេលយប់និងតាមប្រព័ន្ធប្រៃយសណីយ៍）

④ ស្តីពីរបៀបប្រឡងជាលក្ខណៈពិសេសតាមការជ្រើសរើសទូទៅ

ចំណុចសំខាន់ៗ---- នៅពេលចូលរៀន

10. ស្តីពីតំលៃនៃការសិក្សា……16

11. ប្រាក់ជំនួយលើថ្លៃសិក្សាសាលាវិទ្យាល័យ……17

12. ពត៌មានស្តីអំពីប្រពន្ធ័នៃប្រាក់ឧបត្ថម្ភលើថ្លៃសិក្សាសម្រាប់វិទ្យាលយ័ឯកជន……17

13. ការចូលរៀនវិទ្យាល័យសាជាថ្មីម្តងទៀត……18

14. សំណួរទូទៅ……19

កន្លែងទាក់ទងស្តីអំពីសៀវភៅពន្យល់ណែនាំនេះ

គណកម្មាការ ក្រសួងអប់រំខេត្តកាណាហ្គាវ៉ាផ្នែកសិក្សាធិការ ទីចាត់ការផ្នែកអប់រំជ្រើរើសសិស្សចូលប្រឡង・កំណត់ជាក្រុម

神奈川県教育委員会　教育局　高校教育課入学者選抜・定員グループ

☎ 045-210-8084　URL: http://www.pref.kanagawa.jp/docs/dc4/nyusen/nyusen/kanagawa.html

អង្គការបណ្តាញវិប្បធមិចម្រុះខេត្តកាណាហ្គាវ៉ា ＮＰＯ法人多文化共生教育ネットワークかながわ（ＭＥ－ｎｅｔ）

ការិយាល័យ ☎ 045-896-0015（ចន្ទ័. ពុធ. សុក្រ 10:00～17:00） E-mail: info@me-net.or.jp

URL: http://me-net.or.jp/

សៀវភៅណែនាំដែលបានបកប្រែនេះអាចទាញយកពីទំព័រអ៊ីនធឺណិតទាំង២ខាងលើនេះ។

ចំណុចសំខាន់ៗ ---- រហូតដល់ពេលប្រឡង

1. ប្រភេទនៃវិទ្យាល័យ

វិទ្យាល័យនៃប្រទេសជប៉ុនចែកចេញជា 2 ប្រភេទគឺវិទ្យាល័យរដ្ឋ និងវិទ្យាល័យឯកជន។

ចំណែកពេលម៉ោងនៃការសិក្សា ក៏ត្រូវបែងចែកជា 3 ផ្នែកដែរ។

（ឆ្នាំ２０２１វិទ្យាល័យដែលអនុវត្តន៍ជ្រើសរើសសិស្សចូលរៀនមានចំនួនដូចខាងក្រោមនេះ）

（1） ភាពខុសគ្នារវាងវិទ្យាល័យរដ្ឋ និងវិទ្យាល័យឯកជន

| | |
|---|---|
| វិទ្យាល័យរដ្ឋ | .សាងសង់ឡើងដោយស្រុកឬខេត្ត<br>..នៅក្នុងខេត្តកាណាហ្កាវ៉ាមានវិទ្យាល័យរបស់ខេត្ត １３５និងវិទ្យាល័យរបស់ស្រុក １５<br>.ប្រជាជនរស់នៅក្នុងខេត្តកាណាហ្កាវ៉ានេះអាចដាក់ពាក្យចូលប្រឡងបាន<br>(អ្នកមានកន្លែងធ្វើការនៅក្នុងខេត្តកាណាហ្កាវ៉ាក៏អាចដាក់ពាក្យចូលរៀនពេលយប់និងតាមប្រព័ន្ធប្រៃសណីយ៍បានដែរ)<br>【ក្បួនប្រលង】គ្រប់សាលារដ្ឋត្រូវបានបែងចែកការប្រលងជា២ផ្នែកគឺ「ជម្រើសទូទៅ」នឹង「ជម្រើសបែងចែកសាលាយប់ឬរៀនតាមប្រៃណីយ៍」☛ P.4 |
| វិទ្យាល័យឯកជន | .សាងសង់ឡើងដោយឯកជន<br>· គោលការណ៏នៃការបង្រៀនខុសគ្នាទៅតាមវិទ្យាល័យ<br>.នៅក្នុងខេត្តកាណាហ្កាវ៉ា មានវិទ្យាល័យឯកជន ５８<br>【ក្បួនប្រលង】ថ្ងៃប្រលងនឹងខ្លឹមសារពិនិត្យឯកសាររបស់វិទ្យាលយ័នីមួយៗគឺខុសគ្នា។អាចដាក់ពាក្យប្រលងបាន៣ប្រភេទគឺសាលាឯកជន១សាលា「専願(単願)」នឹងប្រលងសាលារដ្ឋ១នឹងសាលាឯកជន១សាលា「併願」នឹងប្រលងសាលាឯកជនច្រើនសាលា「オープン」បើប្រលងជាប់សាលាមួយណាហើយមិនអាចបដិសេធបានទេចាំបាច់ត្រូវចូលរៀននៅសាលាដែលប្រលងជាប់នោះ។ទោះបីជាបដិសេធក៏មិនអាចដាក់ពាក្យប្រលងទៅសាលាថ្មីផ្សេងបានទៀតដែរ។ |

（2） ភាពខុសគ្នារវាងប្រភេទវិទ្យាល័យរៀនពេលថ្ងៃ.រៀនពេលយប់ និងរៀនតាមប្រព័ន្ធប្រៃសណីយ៍

វគ្គសិក្សាចែកចេញជា 3 វគ្គយោងតាមម៉ោងនៃការសិក្សា។

| | |
|---|---|
| កម្មវិធី<br>វិទ្យាល័យពេលថ្ងៃ | រៀងរាល់ថ្ងៃការសិក្សាចាប់ផ្តើមពីព្រឹកម៉ោង 8：40 រហូតដល់ម៉ោង 3：30 ល្ងាច ។ត្រូវរៀនរយៈពេល 3 ឆ្នាំទើបបញ្ចប់ការសិក្សា។ វិទ្យាល័យរដ្ឋមាន１４８ |
| កម្មវិធី<br>វិទ្យាល័យពេលយប់ | ការបែងចែកពេលវេលាសិក្សាមាន( ពេលព្រឹក,ពេលល្ងាច,ពេលយប់) ទៅតាមលក្ខណៈពិសេសនឹងជាក់ស្តែង<br>ភាគច្រើននៃវិទ្យាល័យប្រភេទនេះគឺរៀននាពេលយប់។ វិទ្យាល័យរដ្ឋមាន ２７<br>មានវិទ្យាល័យបត់បែន(Flexible School)គឺជាវិទ្យាល័យដែលអាចសម្រួលម៉ោងរៀនក្នុងមួយថ្ងៃៗតាមជិវភាពរស់នៅប្រចាំថ្ងៃបាន។<br>ត្រូវចំណាយរយៈពេល 4 ឆ្នាំដើម្បីបញ្ចប់ការសិក្សា ក៏ប៉ុន្តែមានវិទ្យាល័យខ្លះអាចបញ្ចប់ការសិក្សាត្រឹមតែ3ឆ្នាំ។ |

| | |
|---|---|
| កម្មវិធី<br>ប្រព័ន្ធប្រៃសណីយ៍ | សៀវភៅមេរៀននិងសៀវភៅលំហាត់-លទ្ធផលដែលកំណត់ក្រិតវិជ្ជានិងការយកពិន្ទុនោះគឺបានមកពីការផ្ញើនៃការសិក្សានិងធ្វើរបាយការណ៍ដោយខ្លួនឯងនៅឯផ្ទះជាមូលដ្ឋាន ។ វិទ្យាល័យរដ្ឋមាន 2 វិទ្យាល័យ ។<br>មិនចាំបាច់មកសាលារៀនជារាងរាល់ថ្ងៃទេ ។តែក្នុង 1 ខែចាំបាច់ត្រូវទៅសាលា 2～3ដងដើម្បីទទួលការពន្យល់ណែនាំមេរៀនដែលគេហៅថា SCHOOLING ។<br>ដើម្បីធ្វើរបាយការណ៍មានសាលាខ្លះឱ្យទៅ SCHOOLINGដែលអនុវត្តនាថ្ងៃធម្មតា ឬក៏មានសិក្សាតាមប្រពន្ធ័ប្រៃសណីយ៍ ។ |

（3） ការខុសគ្នារវាងប្រព័ន្ធថ្នាក់និងប្រព័ន្ធពិន្ទុ

របៀបបែងចែកក្រិតថ្នាក់ ឬ ឆ្នាំសិក្សាមាន 2 ប្រភេទ ។

| | |
|---|---|
| ប្រព័ន្ធយកតាមឆ្នាំសិក្សាជាមូលដ្ឋាន | យោងទៅតាមឆ្នាំសិក្សានិមួយៗ ប្រព័ន្ធថ្នាក់ត្រូវបានក្រិតកម្មវិធីសិក្សាជាច្រើន ។ |
| ប្រព័ន្ធយកតាមពិន្ទុជាមូលដ្ឋាន | ពុំមានការបែងចែកឆ្នាំសិក្សាទេ ។ ប្រព័ន្ធនេះកំណត់យកតាមពិន្ទុជាមូលដ្ឋានសំខាន់ដើម្បីប្រលងបញ្ចប់ថ្នាក់ ។ |

（4） ការរៀនមុខវិជ្ជាទូទៅ-មុខវិជ្ជាបច្ចេកទេស និងមុខវិជ្ជាចំរុះ( មុខវិជ្ជាត្រូវបែងចែកយោងតាម ប្រភេទនៃការសិក្សាវិទ្យាល័យនីមួយៗ) ។

វិទ្យាល័យរដ្ឋនៅក្នុងខេត្តកាណាហ្គាវ៉ា មានមុខវិជ្ជាដូចតទៅនេះ :

| | |
|---|---|
| មុខវិជ្ជាទូទៅ | អក្សរសាស្ត្រ,ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ,ប្រជាពលរដ្ឋ, គណិតវិទ្យា , វិទ្យាសាស្ត្រ , ភាសាអង់គ្លេសជាដើម ។<br>ជាមុខវិជ្ជាទូទៅដែលចាំបាច់ត្រូវសិក្សា ។<br>ប្រព័ន្ធថ្នាក់ (វិទ្យាល័យពេលថ្ងៃមាន １０１, វិទ្យាល័យពេលយប់មាន 11)<br>ប្រព័ន្ធពិន្ទុ (វិទ្យាល័យពេលថ្ងៃមាន１６, វិទ្យាល័យពេលយប់មាន 7, វិទ្យាល័យប្រព័ន្ធប្រៃសណីយ៍មាន 2) |
| មុខវិជ្ជាទូទៅ<br>(ផ្នែកឯកទេស) | ការសិក្សាទៅលើមុខវិជ្ជាឯកទេសបន្ថែមពីលើមុខវិជ្ជាទូទៅ។<br>ក្នុងទីក្រុងយូកូហាម៉ានៃវិទ្យាល័យតូសឺកាក្នុងមុខវិជ្ជាទូទៅមានវគ្គសិក្សាតន្ត្រីដែរ ។<br>ប្រពន្ធ័ពិន្ទុ (វិទ្យាល័យពេលថ្ងៃមាន 1 វិទ្យាល័យ) ។ |
| មុខវិជ្ជាបច្ចេកទេស | កសិកម្ម ,ឧស្សាហកម្ម , ពាណិជ្ជកម្ម , ជលផល , វិជ្ជាមេផ្ទះ , គិលានុបដ្ឋាកម្ម , សុខុមាលភាព គណិត វិទ្យាសាស្ត្រ , កីឡា , តន្ត្រី , សិល្បៈ វិចិត្រសិល្បៈ , អន្តរជាតិ , ទំនាក់ទំនងអន្តរជាតិ , សម្តែងសិល្បៈនិង មុខវិជ្ជាដែលទាក់ទងនិងផ្នែកឧស្សាហកម្មទូទៅទាំង<br>មុខវិជ្ជាទាំងនេះត្រូវសិក្សាយកបច្ចេកទេសជាមូលដ្ឋាន ។<br>ប្រព័ន្ធយកឆ្នាំសិក្សាជាមូលដ្ឋាន(វិទ្យាល័យពេលថ្ងៃមាន 25 , វិទ្យាល័យពេលយប់មាន ３)<br>ប្រព័ន្ធយកពិន្ទុជាមូលដ្ឋាន(វិទ្យាល័យពេលថ្ងៃមាន ８) |
| មុខវិជ្ជាចំរុះ | ទាំង មុខវិជ្ជាទូទៅនិងមុខវិជ្ជាបច្ចេកទេសអាចជ្រើសរើសយកមុខវិជ្ជាដែលចង់សិក្សាដោយយកតាមពិន្ទុជាមូលដ្ឋាន។<br>ប្រព័ន្ធយកតាមពិន្ទុជាមូលដ្ឋាន(វិទ្យាល័យពេលថ្ងៃមាន 8, វិទ្យាល័យពេលយប់មាន ６ ។ |

សូមពិនិត្យសាឡើងវិញ---- នៅពេលប្រឡង

2. គំរោងកម្មវិធីរហូតដល់ពេលប្រឡង (អាចមានការប្រែប្រួលឬអាក់ខានទៅតាមស្ថានភាពរបស់មេរោគឆ្លងប្រភេទថ្មី「កូរ៉ូណា」)

ចំពោះសិស្សដែលបានបញ្ចប់អនុវិទ្យាល័យនៅជប៉ុន ឬអ្នកដែលមានគំរោងនឹងរៀនបញ្ចប់ អនុវិទ្យាល័យ

ចំពោះសិស្សដែលបានបញ្ចប់ការសិក្សាអប់រំគ្រប់ចំនួន 9ឆ្នាំនៅឯបរទេស

ឆ្នាំ ２０２０ ខែ9～10

「សៀវភៅពន្យល់ណែនាំអំពីការប្រឡងចូលវិទ្យាល័យសំរាប់សិស្សដែលភាសាជប៉ុនមិនមែនជាភាសាកំណើត」
ឆ្នាំនេះមិនមានបើកកម្មវិធីពន្យល់ទេ។ដើម្បីទទួលពត៌មានជាភាសាផ្សេងៗស្តីពីការជ្រើសរើសសិស្សចូលរៀននៅវិទ្យាល័យរដ្ឋក្នុងខេត្តកាណាហ្គាវ៉ា សូមពិនិត្យមើលនៅលើគេហទំព័រ http://me-net.or.jp/guidance/ (☞ ទំព័រខាងមុខនឹងខាងក្រោយ)

ឆ្នាំ ２０２០ ចុងខែ10

ការជ្រើសរើសកំណត់ចំនួនសិស្សចូលរៀនវិទ្យាល័យរដ្ឋនឹងមានប្រកាសលើទំព័រកាសែតឬ

ឆ្នាំ ２０２０ ខែ １２

មានបើកទទួលសម្ភាសន៍ នៅតាមអនុវិទ្យាល័យ. ពិនិត្យអំពីកាប្រឡងចូលវិទ្យាល័យ។ 「របៀបប្រឡងពិសេសពីការជ្រើសរើសទូទៅ」 មានបើកទទួលពាក្យនៅតាមអនុវិទ្យាល័យ (☞ទំព័រទី 15)

សូមចូលរួមស្តាប់ការពន្យល់ពី「ក្រុមគណ:កម្មាធិការអប់រំខេត្ត」 និងធ្វើសំណុំពាក្យដាក់ 「លិខិតបញ្ជាក់លក្ខណសម្បត្តិដាក់ពាក្យប្រឡង」 ដែលនឹងធ្វើនៅថ្ងៃទី 5 (ថ្ងៃសៅរ៍) ខែ １２ (☞ទំព័រទី9) 「របៀបប្រឡងពិសេសពីការជ្រើសរើសទូទៅ」គឺមានការពន្យល់ផងដែរ។ (☞ទំព័រទី15)

ឆ្នាំ２０２１ខែ1ទៅ ប្រឡងជ្រើសរើសទូទៅ • ប្រឡងជ្រើសរើសពិសេស (※1) ☞ទំព័រ 4

① ដាក់ពាក្យប្រឡងចូលវិទ្យាល័យ(១សាលា)ដាក់ពាក្យសុំចូលរៀន
② ការផ្លាស់ប្តូរដាក់ពាក្យសុំគឺបានតែ១ដង។
③ ធ្វើការពិនិត្យកំរិតវិជ្ជានឹងការសម្ភាសន៍ផ្ទាល់។
④ ប្រកាសលទ្ធផលចំពោះអ្នកប្រឡងជាប់

ជំរើសរួម,ជំរើសពិសេស,ឬអ្នកដែលប្រឡងជាប់សាលាឯកជនហើយមិនអាចដាក់ពាក្យប្រឡងជ្រើសរើសដោយឡែកឬដាក់ពាក្យប្រឡងលើកទីពីរបានទេ។(※２)

ឆ្នាំ２０２１ខែ3ទៅ ប្រឡងជ្រើសរើសដោយឡែក ☞ទំព័រ 4

① ដាក់ពាក្យឡងចូលវិទ្យាល័យ(១សាលា)ដាក់ពាក្យសុំចូលរៀន
② ការផ្លាស់ប្តូរដាក់ពាក្យសុំគឺបានតែ១ដង។
③ ការពិនិត្យកំរិតវិជ្ជានឹងធ្វើការសម្ភាសន៍ជាដើម។
④ ប្រកាសលទ្ធផលចំពោះអ្នកប្រឡងជាប់

※1 ជំរើសពិសេស,ជ្រើសរើសជនបរទេសនៅក្នុងក្រុងនេះ(ជ្រើសរើស13សាលា)នឹងជ្រើសរើសសិស្សមកពីបរទេស(8សាលា) លទ្ធភាពដែលអាចប្រឡងបានសូមមើលនៅទំព័រទី៥។

※2 ជំរើសលើកទីពីរគឺសាលារៀនធម្មតា,រៀនពេលយប់ជាដើម។ដែលមានសិស្សប្រឡងជាប់ពុំគ្រប់ចំនួនសិស្ស,គេនឹងរើសបន្ថែមទៀតក្នុងពាក់កណ្តាលមិនា។ចំពោះសិស្សរៀនពេលយប់នឹងសិស្សរៀនតាមប្រព័ន្ធប្រៃសណីយ៍,បើប្រឡងជ្រើសរើសនោះមានសិស្សពុំគ្រប់ចំនួននោះគេនឹងប្រឡងរើសថែមទៀតនៅចុងខែ៣។

## 3. សារៈសំខាន់ការប្រឡងជ្រើសរើសនិងតារាងកម្មវិធីចូលវិទ្យាល័យរដ្ឋ

(អាចមានការប្រែប្រួលឬអាក់ខានទៅតាមស្ថានភាពរបស់មេរោគឆ្លងប្រភេទថ្មី 「កូរ៉ូណា」)

**តារាងកម្មវិធីប្រឡងជ្រើសរើសចូលវិទ្យាល័យខេត្តកាណាហ្គាវ៉ាប្រចាំឆ្នាំ ２０２１**

ខែ 1 (មករា)　ខែ2 (កុម្ភៈ)　ខែ 3( មីនា)

| 28 | 29 | 30 | 31 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 1 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| A | A | | | A | | | B | B | | | B | | | | | | | C | C | C | | | | | E | | | | | | | D |

រយៈពេលប្រឡងជ្រើសរើសទូទៅ、 ប្រឡងជ្រើសរើសពិសេស

ខែ 3( មីនា)

| 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | A | A | B | | | B | | | | C | | | C | | | | D | | | | | | | | | | | | |

រយៈពេលប្រឡងជ្រើសរើសដោយឡែក

A : ការដាក់ពាក្យប្រឡង　B : រយៈពេលសុំប្តូរការដាក់ពាក្យ　C : ថ្ងៃពិនិត្យ( ប្រឡងចំណេះដឹងនិងសម្ភាសន៍ជាដើម)　D : ប្រកាសលទ្ធផល

E : ប្រលងបន្ថែម

| លក្ខណៈជ្រើសរើសប្រឡង | កម្មវិធី | រៀនពេលថ្ងៃ ,រៀនពេលយប់ I(*) | វិទ្យាល័យរៀនពេលយប់ II(*) | រៀនតាមប្រព័ន្ធប្រៃសណីយ៍ |
|---|---|---|---|---|
| ប្រឡងជ្រើសរើសទូទៅ<br>・<br>ប្រឡងជ្រើសរើសពិសេស | ប្រកាស | ប្រកាសកំណត់ចំនួនសិស្ស ត្រូវជ្រើសរើសគឺ１００% | ប្រកាសកំណត់ចំនួនសិស្ស ត្រូវជ្រើសរើសគឺ８０% | |
| | សំណុំពាក្យ | ដាក់ពាក្យលើមុខវិជ្ជានីមួយៗការដាក់ពាក្យគឺត្រូវមាន សំណុំពាក្យនិង លិខិតសំភាសន៍ ☞ទំព័រ6<br>អាចប្តូរការដាក់ពាក្យបានតែម្តងទេ ☞ទំព័រ 10 | | |
| | ពិនិត្យ | ប្រឡងចំណេះដឹង និង ធ្វើសំភាសន៍ ☞ទំព័រ 11<br>មានវិទ្យាល័យខ្លះអនុវត្តន៍របៀបប្រឡងពិសេស ។ | | បទសំភាសន៍ ឬ តែងសេចក្តី ☞ទំព័រ11 |
| | ជ្រើសរើស | ជ្រើសរើសទូទៅសូមមើលពីរបៀបជ្រើសរើសនៅ ☞ទំព័រ12<br>ជ្រើសរើសពិសេស ☞ជ្រើសរើសដោយមើលលិខិតអង្កេតការ (**) | | ជ្រើសរើសរួមគ្នាក្រោយពីទទួលលទ្ធផលពីការប្រឡងនិងពិនិត្យឯកសារ ។ |
| ប្រឡងជ្រើសរើស ដោយឡែក | ប្រកាស | មិនអនុវត្តន៍ទេ | ប្រកាសកំណត់ចំណួនសិស្សដែលត្រូវជ្រើសរើសគឺ ２０% ។<br>ប៉ុន្តែ,វិទ្យាល័យដែលប្រកាសជ្រើសរើសសិស្សទូទៅមិនទាន់គ្រប់ចំណួនសិស្ស ទេនោះ នឹង ជ្រើសរើសសិស្សបន្ថែមអោយគ្រប់ ចំនួនទៀត ។ | |
| | សំណុំពាក្យ | | ដាក់ពាក្យលើមុខវិជ្ជានិមួយៗការដាក់ពាក្យគឺត្រូវមាន សំណុំពាក្យនិង លិខិត បទសំភាសន៍ ☞ទំព័រ 6<br>អាចប្តូរការដាក់ពាក្យបានតែម្តងទេ ☞ទំព័រ 14 | |
| | ពិនិត្យ | | ប្រឡងចំណេះនិងបទសំភាសន៍ ☞ទំព័រ 14មានវិទ្យាល័យខ្លះអនុវត្តន៍ របៀបប្រឡងពិសេស ។ | បទសំភាសន៍ ឬ តែងសេចក្តី ☞ទំព័រ14 |
| | ជ្រើសរើស | | ជ្រើសរើសទូទៅ<br>សូមមើលពីរបៀបជ្រើសរើសនៅ☞ទំព័រ12<br>ជ្រើសរើសពិសេស<br>ជ្រើសរើសដោយមើលលិខិតអង្កេតការ | ជ្រើសរើសរួមគ្នាក្រោយពីទទួលលទ្ធផលពីការប្រឡងរួចហើយ ។ |

＊ វិទ្យាល័យរៀនពេលយប់ I･･･ក្រៅពីរៀនពេលយប់មានវិទ្យាល័យផ្សេងទៀតគឺ 県立横浜明朋高校(けんりつよこはまめいほうこうこう)、県立川崎高校(けんりつかわさきこうこう)、県立厚木清南高校(けんりつあつぎせいなんこうこう)、県立相模向陽館高校(けんりつさがみこうようかんこうこう)、横浜市立横浜総合高校(よこはましりつよこはまそうごうこうこう)、川崎市立川崎高校(かわさきしりつかわさきこうこう)

វិទ្យាល័យរៀនពេលយប់ II･･･វិទ្យាល័យរៀនពេលយប់។ ＊គឺលើកលែង វិទ្យាល័យរៀនពេលយប់ I

＊＊វិទ្យាល័យ Sagamihara Yaei (相模原弥栄高校(さがみはらやえいこうこう)) មានការជ្រើសរើសពិសេសដោយពិនិត្យមើលទៅលើលិខិតអង្កេតការ។

## 4. លក្ខណៈសម្បត្តិនិងឯកសារសំខាន់ផ្សេងៗនៃការដាក់ពាក្យប្រឡង

（1） លក្ខណៈសម្បត្តិនៃការដាក់ពាក្យប្រឡង

ការជ្រើសរើសទូទៅនៃលក្ខណៈសម្បត្តិរបស់សិស្ស

| ដាក់ពាក្យចូលវិទ្យាល័យ | លក្ខណៈសម្បត្តិនៃការដាក់ពាក្យប្រឡង |
|---|---|
| ការជ្រើសរើសទូទៅ<br>សំរាប់វិទ្យាល័យរៀនពេលថ្ងៃ | បន្ទាប់ទៅនេះ ចំពោះអ្នកដែលមានចំណុច ត្រូវនឹងABC<br>A អ្នកដែលចាប់កំណើតក្នុងឬមុនថ្ងៃទី 1 ខែ 4 ឆ្នាំ ２００６<br>B<br>សិស្សដែលបានបញ្ចប់អនុវិទ្យាល័យក្នុងប្រទេសនិងបានបញ្ចប់ការសិក្សាចំនួន៩ឆ្នាំនៅបរទេស ឬមួយក៏ដឹងថាត្រូវបញ្ចប់ការសិក្សានៅអនុវិទ្យាល័យក្នុងថ្ងៃទី ３１ខែ３ ឆ្នាំ ２０２１នេះ។<br>C សិស្សដែលកំពុងរស់នៅជាមួយអាណាព្យាបាលមានអាសយដ្ឋាននៅក្នុងខេត្តកាណាហ្កាវ៉ា ឬក៏ត្រូវផ្លាស់ទីលំនៅមករស់នៅក្នុងទីខេត្តកាណាហ្កាវ៉ានេះមុនថ្ងៃទី １ខែ４ ឆ្នាំ ２０２１។ |
| ការជ្រើសរើសទូទៅសំរាប់វិទ្យាល័យ<br>រៀនពេលយប់-រៀនតាមប្រព័ន្ធប្រៃសណីយ៍ | បន្ថែមលើចំណុច ＡＢ៛អ្នកមានប្រភេទក្នុង Ｄ<br>D សំរាប់សិស្សដែលរស់នៅក្នុងទីខេត្តកាណាហ្កាវ៉ា និងសំរាប់សិស្សដែលមានគំរោងផ្លាស់ប្តូរទីលំនៅមកក្នុងខេត្តកាណាហ្កាវ៉ា ត្រឹមថ្ងៃទី １ ខែ４ ឆ្នាំ２０２１<br>(អ្នកមានទីកន្លែងធ្វើការនៅក្នុងខេត្តកាណាហ្កាវ៉ាក៏បានដែរ) |

ការដាក់ពាក្យលក្ខណៈចូលប្រឡងសំរាប់ករណីពិសេស

| | |
|---|---|
| ការជ្រើសរើសករណីពិសេស<br>សំរាប់ជនជាតិបរទេសដែលរស់នៅក្នុងខេត្ត<br>（ការប្រឡងជ្រើសរើសសិស្សវិទ្យាល័យគឺសិស្សថ្ងៃ១២សាលា,សិស្សយប់១សាលា ☞ទំព័រទី １３） | បន្ថែមលើចំណុចＡＢＣ(រៀនពេលយប់ ＡＢＤ) អាចដាក់ពាក្យសំរាប់ប្រភេទＥ និងＦ<br>Ｅ រស់នៅរយៈពេល３ ឆ្នាំ គិតមកដល់ថ្ងៃទី１ ខែ２ ឆ្នាំ ２０２１ នេះទៅ(លើកលែងតែរយៈពេលស្នាក់នៅនោះមុនពេលចូលរៀនសាលាបឋមសិក្សា)។<br>Ｆ ចំពោះសិស្សដែលមានសញ្ជាតិបរទេសដែលមានទិដ្ឋាការជប៉ុនរយៈពេល៣ឆ្នាំ ឬក៏បានយកសញ្ជាតិជប៉ុន（គិតត្រឹមថ្ងៃទី 1ខែ2 ឆ្នាំ 2021）។ |
| ការជ្រើសរើសករណីពិសេស<br>សំរាប់សិស្សត្រឡប់មកពីបរទេស<br>（ប្រកាសទទួលសិស្សរៀនវិទ្យាល័យពេលថ្ងៃមាន 8វិទ្យាល័យ ☞ទំព័រទី １３） | បន្ថែមលើចំណុចＡＢＣ, សំរាប់អ្នកមានប្រភេទត្រូវចំណុច Ｇ<br>Ｇ រយៈពេលអាណាព្យាបាលរស់នៅឬធ្វើការទីនោះជាដើម ជាង 2 ឆ្នាំ នៅឯបរទេស ចំពោះអ្នកបានត្រឡប់មកប្រទេសវិញក្រោយថ្ងៃទី 1**ខែ**4 **ឆ្នាំ** ２０１８ |

（２） ឯកសារសំខាន់ផ្សេងៗសំរាប់ការដាក់ពាក្យប្រឡង

| | |
|---|---|
| ការជ្រើសរើសជាទូទៅ | ① ដាក់ពាក្យចូលរៀន<br>② តម្លៃប្រឡងចូល（※１）<br>※１ បំណាច់ឆ្នាំមុនគឺ រៀនពេលថ្ងៃ 2,200យ៉េន<br>រៀនពេលយប់ 950យ៉េន(តែវិទ្យាល័យស្រុកយ៉ូកូហាម៉ាពេលយប់ 650យ៉េន),<br>រៀនតាមប្រព័ន្ធប្រៃសណីយ៍ 0យ៉េន<br>③ លិខិតអង្កេត ការសិក្សា(ធ្វើចេញពីអនុវិទ្យាល័យ)（※２）<br>※2 ចំពោះសិស្សដែលបានបញ្ចប់អនុវិទ្យាល័យនៅបរទេស រយះពេល 9 ឆ្នាំឬដែលមានអាយុលើសពី２０ឆ្នាំឡើងទៅគឺមិនចាំបាច់ដាក់ លិខិតនេះទេ។(គិតត្រឹមថ្ងៃទី 1ខែ4 ឆ្នាំ 2021)<br>④ លិខិតផ្សេងៗ （លិខិតដែលកំណត់ដោយសាលាដែលអ្នកបានដាក់ពាក្យ។） |

ប្រកាសជ្រើសរើសពិសេស

| | |
|---|---|
| ការជ្រើសរើសករណីពិសេស（សំរាប់ជនជាតិបរទេសរស់នៅក្នុងខេត្ត） | បន្ថែមលើចំណុច①②③④<br>⑤ លិខិតបញ្ជាក់ពីសញ្ជាតិបរទេសឬលិខិតសំគាល់ការទទួលបានសញ្ជាតិជប៉ុនក្នុងរយៈ 3 ឆ្នាំចុងក្រោយ<br>⑥ លិខិតបញ្ជាក់ការរស់នៅក្នុងប្រទេសជប៉ុនក្នុងរយៈពេល 3 ឆ្នាំចុងក្រោយ （លិខិតឆ្លងដែន） |
| ការជ្រើសរើសករណីពិសេស（សំរាប់សិស្សត្រឡប់មកពីបរទេស） | បន្ថែមលើចំណុច①②③④<br>⑦ លិខិតបញ្ជាក់ការរស់នៅឯបរទេសរយះពេល2ឆ្នាំឡើងទៅអាស្រយ័ទៅលើទីលំនៅនិងលិខិតបញ្ជាក់ទីការងាររបស់អាណាព្យាបាល។（※３）<br>⑧ លិខិតបញ្ជាកការត្រឡប់មកពីបរទេសវិញក្រោយថ្ងៃទី １ខែ4 ឆ្នាំ ２０１８（※3）<br>※3 លិខិតបញ្ជាក់ពីក្រុមហ៊ុន ឬ លិខិតឆ្លងដែនរបស់អាណាព្យាបាលនិងសាម៉ីខ្លួនជាដើម។ |

○បើដាក់ពាក្យនៅវិទ្យាលយ័ណាដែលមានរៀនពីព្រលឹមហើយនឹងចាប់ផ្តើមពីថ្ងៃត្រង់ទៅសិស្សអាចសរសេរជម្រើស2នៅលើក្រដាស់ដាក់ពាក្យ។
បើដាក់ពាក្យសាលាណាដែលមានបង្រៀនកសិកម្ម、ឧស្សាហកម្ម、
ពាណិជ្ជកម្មនឹងជលផលសិស្សអាចរើសយក2មុខវិជ្ជា។បើជំរើសទី1ជាប់ជំរើសទី2មិនអាចទទួលបានទេ។
វិទ្យាលយ័របស់រដ្ឋឈ្មោះ 「យ៉ូកូហាម៉ាខុខឹសៃ」 អាចដាក់ពាក្យត្រឹម២ជម្រើសគឺ 「ខុខឹសៃហុងតៃ」 នឹង「ខុខឹសៃកាក់ខុខឹសៃបាខារ៉ូលេអាខូស១ឈ្មោះមិនទាន់ប្រាកដជ」
「ខុខឹសៃហុងតៃ」 គឺជាផ្នែកមុខវិជ្ជាអន្តរជាតិដែលដកចេញពី「ខុខឹសៃកាក់ខុខឹសៃបាខារ៉ូលាខូស」ហើយ 「ខុខឹសៃកាក់ខុខឹសៃបាខារ៉ូលាខូស」 គឺជាផ្នែកដែលបានបង្កើតចេញពី「អង្គការខុខឹសៃបាខារ៉ូលា」 ដែលកំពុងដាក់ពាក្យបង្កើតសាលាហើយឈ្មោះនេះមិនទាន់កំណត់ជាផ្លូវការទេ។១ដូចទៅខាងក្រោមជ

## ５．ស្តីពីប្រព័ន្ធប្រាក់ថ្លៃប្រឡងវិទ្យាល័យរដ្ឋ និងការកាត់បន្ថយប្រាក់ថ្លៃចូលរៀន

○ អ្វីដែលហៅថាប្រាក់ថ្លៃប្រឡង និងប្រពន្ធ័កាត់បន្ថយប្រាក់ថ្លៃចូលរៀន គឺ
អ្នកដែលបញ្ហាជីវភាព មានការលំបាកលើការចំណាយ ប្រាក់ថ្លៃប្រឡង・ប្រាក់ថ្លៃចូលរៀន(ប្រាក់ចូលរៀនដំបូង) ប្រព័ន្ធនេះគឺ
កាត់បន្ថយមួយចំនួន ឬលើកលែងទាំងអស់តែម្តង។(ប្រាក់ថ្លៃចូលរៀន☞ទំព័រទី 16)

○ របៀបដាក់ពាក្យសុំ
សូមពិភាក្សាជាមួយនឹងការិយាល័យនៃវិទ្យាល័យដែលដាក់ពាក្យសុំចូលរៀន។ ការដាក់ពាក្យសុំបន្ថយប្រាក់នេះ គឺមានពេលកំណត់
ប្រាក់ថ្លៃប្រឡង ..................គឺត្រូវដាក់មុន ថ្ងៃដែលត្រូវដាក់ពាក្យប្រឡង
ប្រាក់ថ្លៃចូលរៀន.................គឺត្រូវដាក់មុន ត្រឹមថ្ងៃដែលត្រូវដាក់ពាក្យចូលរៀន （បន្ទាប់ពីប្រកាសលទ្ធផលប្រឡងជាប់ ក្នុងរយះពេលប៉ុន្មានថ្ងៃ）
（★ក្នុងករណីដែលហួសការកំណត់ ការដាក់ពាក្យនោះចាត់ទុកជាមោឃៈ）

【កន្លែងទាក់ទង】
・នៅតាមការិយាល័យវិទ្យាល័យដែលដាក់ពាក្យចូលរៀន
ឬក៏គណៈកម្មការអប់រំប្រចាំខេត្ត
・神奈川県教育委員会教育局財務課財務指導グループ（かながわけんきょういくいいんかいきょういくきょくざいむかざいむしどう） ទូរស័ព្ទលេខ：045-210-8113(ខ្សែផ្ទាល់-ជាភាសាជប៉ុន)

## 6. លិខិតអង្កេតការ

លិខិតអង្កេតការគឺសាលាអនុវិទ្យាល័យជាអ្នកចេញអោយចំពោះអ្នកត្រូវប្រឡងចូលវិទ្យាល័យនេះគឺជាឯកសារសំខាន់ដែលត្រូវរក្សាទុក។

第11号様式
**様式見本**

# 調　　査　　書

| ※ 受検番号 | |
|---|---|

| | | | | |
|---|---|---|---|---|
| 志願先高等学校 | ○○○○ | 立 | ○○ | 高等学校 |
| | ○○ | 科 | | （コース・部） |

| | | | | | |
|---|---|---|---|---|---|
| 学籍の記録 | ふりがな | ○○○○　○○○○ | 性別 | 入学年月 | 平成・令和　年　月　中学校<br>第　学年　入学・編入学 |
| | 氏名 | ○○　○○ | ○ | 転入学年月 | 平成・令和　年　月　中学校<br>第　学年　転入学 |
| | 生年月日 | 平成　○○　年　○　月　○○　日生 | | | |
| | 現住所 | ○○市○○町　○丁目○番○号<br>○○マンション○○ | | 卒業年月 | 平成・令和　年　3月　同　中学校　卒業見込・卒業 |

### 各教科の学習の記録

| 教科 | 観点別学習状況 | 2年 評価 | 2年 評定 | 3年 評価 | 3年 評定 |
|---|---|---|---|---|---|
| 国語 | 国語への関心・意欲・態度 | A | 4 | A | 4 |
| | 話す・聞く能力 | B | | B | |
| | 書く能力 | B | | A | |
| | 読む能力 | A | | A | |
| | 言語… | A | | A | |
| 社会 | 社会… | | 4 | A | 5 |
| | 社会… | | | A | |
| | 資料… | A | | A | |
| | 社会的事象についての知識・理解 | A | | A | |
| 数学 | 数学への関心・意欲・態度 | B | 3 | A | 3 |
| | 数学的な見方や考え方 | B | | B | |
| | 数学的な技能（数学的な表現・処理） | B | | B | |
| | 数量や（数量,）図形などについての知識・理解 | B | | B | |
| 理科 | 自然事象への関心・意欲・態度 | B | 2 | B | 3 |
| | | C | | B | |
| | | C | | B | |
| | | B | | B | |
| 音楽 | | | 3 | B | 3 |
| | 音楽表現の創意工夫（音楽的な感受や表現の工夫） | B | | B | |
| | 音楽表現の技能（表現の技能） | B | | B | |
| | 鑑賞の能力 | A | | A | |
| 美術 | 美術… | A | 4 | A | 4 |
| | 発想… | B | | B | |
| | 創造… | B | | A | |
| | 鑑賞… | A | | A | |
| 保健体育 | 運動や健康・安全への関心・意欲・態度 | A | 5 | A | 4 |
| | 運動や健康・安全についての思考・判断 | A | | B | |
| | 運動の技能 | A | | A | |
| | 運動や健康・安全についての知識・理解 | A | | A | |
| 技術・家庭 | 生活や技術への関心・意欲・態度 | A | 4 | A | 4 |
| | 生活を工夫し創造する能力 | B | | A | |
| | 生活の技能 | A | | A | |
| | 生活や技術についての知識・理解 | A | | B | |
| 外国語（英語） | コミュニケーションへの関心・意欲・態度 | A | 4 | A | 5 |
| | 外国語表現の能力（表現の能力） | A | | A | |
| | 外国語理解の能力（理解の能力） | B | | A | |
| | 言語や文化についての知識・理解 | A | | A | |
| | 小計　※ | | | | |
| | | | | | （×2.0） |
| | 計　※ | | | | |

①ការវិភាគកំរិតវិជ្ជាមាន៣លំដាប់ត្រូវបានកំណត់តាមមុខវិជ្ជានិងការពិនិត្យពិន្ទុ

②ការវិភាគកម្រិតវិជ្ជាសរុបមាន៥លំដាប់សម្រាប់ថ្នាក់ឆ្នាំទី៣ដែលធ្វើឡើងត្រឹមខែធ្នូ

③ការវិភាគទៅតាមមុខវិជ្ជានីមួយៗដែលមាន៥លំដាប់សំរាប់ថ្នាក់ទី២ក្នុងរយៈពេលពេញមួយឆ្នាំ

### 総合的な学習の時間の記録

| 学年 | 学習活動の内容 | 活動状況及び所見 |
|---|---|---|
| 2年 | 身近な環…いて考え… | 身近な環境問題として、… |
| 3年 | 地域に住むさまざまな国の人々を知る | 地域に住む諸外国の人々へのインタビューをもとに、それぞれの国の文化についてまとめ、工夫を凝らして発表した。 |

④ស្តីពីការកត់ហេតុអំពីការសិក្សាសារុបទាំអស់លើការសិក្សា ពេលវេលា គឺត្រូវបានសរសេរទុក

### 総合所見及び諸活動の記録

**特別活動等の記録**

国語係　（1年）
旅行委員（2年）
美化委員（3年）
文化祭実行委員（3年）
柔道部（1～3年）

⑤កំណត់ហេតុរយៈពេល៣ឆ្នាំនៅអនុវិទ្យាល័យស្តីពីស្ថានភាពការសិក្សានៅសាលានិងសកម្មភាពទូទៅ

**行動の記録及び所見**

委員会活動や学校行事…常にリーダーシップを発揮し活…委員として清掃活…
柔道部では、目…て部員をよくまと…
また、思いやり…からの信頼も厚い…

⑥កំណត់នូវការលូតលាស់រយៈពេល៣ឆ្នាំកន្លងមកកាលនៅអនុវិទ្យាល័យ ការប៉ិនប្រសព្វមុខជំនាញ, ចរិតលក្ខណៈ

本書の記載事項に誤りのないことを証明する。

令和　　年　　月　　日

中学校名

校長氏名　　印

記載者氏名　　印

## 7. លិខិតសម្ភាសន៍

លិខិតសម្ភាសន៍នេះគឺ សិស្សចូលប្រឡងត្រូវសរសេរវត្ថុបំណងដោយខ្លួនឯងនៅពេលចូលត្រូវយកភ្ជាប់ជាមួយនិងលិខិតសុំចូលសាលា។
នេះគឺជាឯកសារអមសម្រាប់ប្រើនៅពេលធ្វើការសម្ភាសន៍ អត្ថន័យក្នុងឯកសារពុំត្រូវបានវាយតំលៃទេ។

第 14 号様式

**面　接　シ　ー　ト**

| ※受　検<br>番　号 | |
|---|---|

| | | | |
|---|---|---|---|
| 志願者<br>氏　名 | ﾌﾘｶﾞﾅ | 中学校名 | 立　　　　中学校 |
| 志願先 | （県・市）立　　　　高等学校　　　　科 | | コース<br>部 |

◎　面接の質問内容の参考とするため、次のことについて記入してください。2、3については、取組み内容も含めて記入してください。
◎　このシートは面接の際の参考資料で、直接に選考資料にはしません。

1　なぜこの学校に入学したいのですか。

「1 ហេតុអ្វីទើបអ្នកចង់ចូលរៀនសាលានេះ?」 ចំពោះអ្នកចង់ដាក់ពាក្យសុំចូលរៀនវិទ្យាល័យនេះ សូមសរសេរស្ដីអំពីមូលហេតុចង់មកចូលរៀន ឬក្រោយពីការចូលរៀនហើយនោះតើនឹងអាចចូលចិត្ត,ចាប់អារម្មណ៍និងចង់ជំរុញឱ្យមានការរីកចំរើនណាមួយជាដើម។

2　中学校での教科等の学習活動に対して、どのような意欲をもって取り組みましたか。

「2 តើកាលនៅរៀនអនុវិទ្យាល័យ តើមានការហ្វឹកហាត់និងការចូលចិត្តចំពោះមុខវិជ្ជាដាយរបៀបណាសូមសរសេរអំពីការខំប្រឹងប្រែង នឹងការចូលចិត្ត, ចំណាប់អារម្មណ៍និង ការរំពឹងទុកតាមវិធីណាខ្លះសូមសរសេរ។

3　中学生のときに教科等以外の活動に対して、どのような意欲をもって取り組みましたか。
（学校外の取組みでも構いません。）

「3 តើកាលនៅរៀនអនុវិទ្យាល័យ ក្រៅពីការសិក្សា តើមានការហ្វឹកហាត់និងធ្វើឱ្យមានការចូលចិត្តចំពោះមុខវិជ្ជាដោយរបៀបណា」 សូមសរសេរអំពីការខំប្រឹងប្រែង ធ្វើអ្វីមួយលក្ខណៈជាក្រុម,កីឡា, ការស្ម័គ្រចិត្តចូលរួមជួយសង្គមក្រៅពីសាលាជាដើម ។ល ។

4　自分自身のよいところはどのようなところだと考えていますか。

「4 ប្រាប់ចំណុចល្អរបស់ខ្លួនអ្នក」 អ្នកគួរសរសេរពីចំណុចល្អដែលខ្លួនមាន ,「ចំពោះខ្លួនខ្ញុំគឺមានចំណុចល្អ--ជាដើម」 គឺសរសេរដូចជា ការប៉ិនប្រសព្វពីចំណុចពិសេសនិងគុណសម្បត្តិរបស់ខ្លួនផ្ទាល់ ។

【記入上の注意】 1 ※の欄は記入しないこ
2 枠 自筆で記入する

សូមប្រយ័ត្ននៃការសរសេរ

1　កន្លែងតារាងដែលមានសញ្ញា ※ សូមកុំសរសេរលើ ។

2　សូមសរសេរនៅក្នុងរង្វង់ ។អាចប្រើខ្មៅដៃសរសេរ ។ហាមបិតរូបថតជាដើម ។

## 8. ការបំពេញឯកសារសំរាប់សិស្សបានបញ្ចប់ការអប់រំគ្រប់៩ឆ្នាំនៅឯបរទេស

(អាចមានការប្រែប្រួលឬអាក់ខានទៅតាមស្ថានភាពរបស់មេរោគឆ្លងប្រភេទថ្មី 「កូរ៉ូណា」)

លក្ខណៈសម្បត្តិនៃការដាក់ពាក្យប្រឡងត្រូវសុំអនុញ្ញាតិក្នុងការដាក់ពាក្យដើម្បីមានសិទ្ធចូលប្រឡងជាចាំបាច់ ។

សូមអញ្ជើញចូលរួមស្តាប់បទបង្ហាញដូចមាននៅខាងក្រោមនេះ ។

បទបង្ហាញរៀបចំដោយគណៈកម្មាធិការក្រសួងអប់រំខេត្តកាណាហ្គាវ៉ា ។ (ចំពោះអ្នករស់នៅក្រៅខេត្ត , អ្នកកើតនៅបរទេស , មានអ្នកបកប្រែ)

ថ្ងៃទី5(សៅរ៍)ខែ12ចាប់ផ្តើមពីម៉ោង14：00ទៅ　ធ្វើនៅយ៉ូកូហាម៉ាស៊ិជឺរីមីខូកៃដូជាន់ទី 6

ទីតាំង:យ៉ូកូហាម៉ាស៊ិជឺរីមីខឹថុយ៉ូអូកាចូ2-1ហ្វឺហ្គា1ហ្គូរកាន់

(ដើរពីស្ថានីយ 「ជឺរីមី」 រថភ្លើងខ្សែJR ខេយហ៊ិនថូហុខឹចេញពីផ្លូវខាងកើតដើរប្រហែល 1 នាទី

អាចដើរពីស្ថានីយ 「ខេយខ្ញឹជឺរីមី」 ខ្សែរខេយហ៊ិនខ្យ៊ឹកូ ចេញពីផ្លូវខាងកើតដើរប្រហែល 5 នាទី)




★ចំពោះសិស្សកំពុងរៀននៅសាលាអនុវិទ្យាល័យរដ្ឋក្នុងខេត្តកាណាហ្គាវ៉ាមិនអាចចូលរួមបានទេ។

○　របៀបនៃការដាក់ពាក្យ

【សិស្សនិងអ្នកអាណាព្យាបាលដែលកំពុងរស់នៅជាមួយអាណាព្យាបាលក្នុងខេត្ត（ករណីសំរាប់សិស្សដែលប្រឡងចូលសាលារៀនពេលថ្ងៃ）】

ចាប់ពីខែ 12 ថ្ងៃទី 7 (ថ្ងៃច័ន្ទ)រហូតដល់ខែ1 ថ្ងៃទី 19(អង្គារ) សូមដាក់ពាក្យ「សុំការយល់ព្រមសិទ្ធិចូលប្រឡង」

ទៅគណៈកម្មាធិការសិក្សាធិការខេត្ត（ការិយាល័យគំរោងការអប់រំវិទ្យាល័យ）។ （ផែនទី ☞ ទំព័រទី １８）

【ឯកសារផ្សេងៗ】

① លិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្នរបស់សិស្សនិងអ្នកអាណាព្យាបាលឬបង្ហាញលិខិតថាគំរោងនឹងស្នាក់នៅ

(បញ្ជាក់កន្លែងរស់នៅឬលិខិតបញ្ជាក់ពីទំនាក់ទំនងរបស់សាម៉ីខ្លួននិងអាណាព្យាបាល ឬក៏បណ្ណ័បញ្ជាក់អាសយដ្ឋានផ្សេងទៀត )

② លិខិតបញ្ជាក់ពីការបញ្ចប់សិក្សាអប់រំគ្រប់៩ឆ្នាំឬមានគំរោងនឹងបញ្ចប់អនុវិទ្យាល័យនៅបរទេស（សញ្ញាប័ត្របញ្ចប់អនុវិទ្យាល័យនៅបរទេសជាដើម）

③ លិខិតបញ្ជាក់ដែលអាចមានសិទ្ធិដាក់ពាក្យចូលសាលា（តាមគំរោង លេខ１５）※

ប្រសិនបើសញ្ញាប័ត្របានត្រូវទទួលស្គាល់ដោយវិទ្យាល័យប្រចាំខេត្តកាណាហ្គាវ៉ាហើយនោះ គេនឹងប្រគល់「លិខិតបញ្ជាក់មានសិទ្ធិចូលប្រឡង」។

លិខិតបញ្ជាក់នេះត្រូវភ្ជាប់ជាមួយនឹងលិខិតដាក់ពាក្យចូលរៀននៅវិទ្យាល័យដែលត្រូវចូលរៀន។

【ចំពោះអាណាព្យាបាលដែលមិនរស់នៅក្នុងខេត្តកាណាហ្គាវ៉ា（សិស្សក៏នៅតែមានលក្ខណៈសម្បត្តិដាក់ពាក្យប្រឡង រៀនពេលយប់ និងតាមប្រព័ន្ធប្រៃសណីយ៍】

វិទ្យាល័យរដ្ឋប្រចាំខេត្តកាណាហ្គាវ៉ា（ប្រព័ន្ធរៀនពេលយប់ប្រព័ន្ធប្រៃសណីយ៍）អាចទទួលបាននូវការដាក់ពាក្យចូលរៀននៅតាមការិយាល័យនៃវិទ្យាល័យដែលត្រូវចូលរៀន។

សិស្សត្រូវរៀបចំឯកសារសំខាន់ៗដូចដែលបានប្រាប់នៅខាងលើនេះដើម្បីដាក់ភ្ជាប់ទៅជាមួយនឹងលិខិតដាក់ពាក្យចូលរៀនទៅវិទ្យាល័យ（តាមគំរោង លេខ１８）។

★ សំរាប់ប្រព័ន្ធរៀនពេលយប់ និងប្រព័ន្ធរៀនតាមការឆ្លើយឆ្លង សិស្សអាចមានសិទ្ធប្រឡងចូលបានដោយមិនចាំបាច់មានអ្នកអាណាព្យាបាលរស់នៅក្នុងខេត្តកាណាហ្គាវ៉ា ឬក៏ធ្វើការនៅក្នុងខេត្តកាណាហ្គាវ៉ានោះទេ។

※ លិខិតបញ្ជាក់ ការមានសិទ្ធិដាក់ពាក្យចូលសាលា（តាមគំរោងដែលខេត្តកំណត់ឡើង）មានគំរោងខុសគ្នារវាងសាលារៀនពេលថ្ងៃ និងសាលារៀនពេលយប់ព្រមទាំងសាលារៀនតាមប្រព័ន្ធប្រៃសណីយ៍។

【ទីកន្លែងទាក់ទង】

ទីចាត់ការផ្នែកអប់រំនិងផ្នែករៀបចំគំរោងចំនួនសិស្សចូលរៀន

ទូរស័ព្ទលេខ : 045-210-8084 〔ខ្សែផ្ទាល់-ជាភាសាជប៉ុន〕

## 9.ស្តីពីការប្រឡងជ្រើសរើសចូលវិទ្យាល័យរដ្ឋ（អាចមានការប្រែប្រួលឬអាក់ខានទៅតាមស្ថានភាពរបស់មេរោគឆ្លងប្រភេទថ្មី「កូរ៉ូណា」）

（1）ការប្រឡងជ្រើសរើសទូទៅ ឬជ្រើសរើសជាករណីពិសេស ការដាក់ពាក្យនិងកម្មវិធីពិនិត្យ

| ពិនិត្យនិងដាក់ពាក្យ | ពេលវេលា | ទីកន្លែង |
|---|---|---|
| ការដាក់ពាក្យប្រឡង | 〈រៀនពេលថ្ងៃ〉 ខែ 1ថ្ងៃទី ２８ (ព្រហស្បត៍)・ថ្ងៃទី ２９ (សុក្រ) 9 :00～12:00、13:00～16:00<br>ខែ 2ថ្ងៃទី1 (ចន្ទ័) 9 :00～12:00<br>〈រៀនពេលយប់＊〉 ខែ 1ថ្ងៃទី ２８ (ព្រហស្បត៍)・ថ្ងៃទី ２９ (សុក្រ) 14:00～19:00<br>ខែ 2ថ្ងៃទី1 (ចន្ទ័) 14:00～16:00<br>〈ប្រព័ន្ធប្រៃសណីយ៏〉 ខែ 1ថ្ងៃទី28 (ព្រហស្បត៍)・ថ្ងៃទី29 (សុក្រ) 9 :00～12:00、13:00～16:00<br>ខែ 2ថ្ងៃទី1 (ចន្ទ័) 9 :00～12:00 | វិទ្យាល័យ<br>ដាក់ពាក្យប្រឡង |
| រយៈពេលសុំប្តូរពាក្យប្រឡង | 〈រៀនពេលថ្ងៃ〉 ខែ2ថ្ងៃទី 4 (ព្រហស្បត៍)・ថ្ងៃទី 5 ((សុក្រ) 9 :00～12:00、13:00～16:00<br>ខែ2 ថ្ងៃទី8(ចន្ទ័) 9 :00～12:00<br>〈រៀនពេលយប់＊〉 ខែ2ថ្ងៃទី 4 (ព្រហស្បត៍)・ថ្ងៃទី 5 ((សុក្រ) 14:00～19:00<br>ខែ2 ថ្ងៃទី8(ចន្ទ័) 9 :00～12:00<br>〈ប្រព័ន្ធប្រៃសណីយ៏〉 ខែ2ថ្ងៃទី 4 (ព្រហស្បត៍)・ថ្ងៃទី 5 (សុក្រ) 9 :00～12:00、13:00～16:00<br>ខែ2 ថ្ងៃទី8(ចន្ទ័) 9 :00～12:00 | មានបញ្ជាក់<br>ខាងក្រោម★ |
| ថ្ងៃប្រឡង | ប្រឡងចំណេះដឹង：ខែ**2**ថ្ងៃទី**１５**(ចន្ទ័)<br>សម្ភាសន៏・ពិនិត្យលក្ខណ:សម្បត្តិ：ខែ**2**ថ្ងៃទី**１５**(ចន្ទ័)・ថ្ងៃទី**１６**（អង្គារ）<br>・ថ្ងៃទី**１７**（ពុធ）<br>※រយៈពេលដូចខាងលើនេះគឺមានសរសេរនៅលើក្រដាសប្រឡង<br>＊＊ប្រលងបន្ថែម ខែ**2**ថ្ងៃទី**２２**(ចន្ទ័) | វិទ្យាល័យ<br>ដាក់ពាក្យប្រឡង |
| ប្រកាសលទ្ធផលប្រឡង<br>ទទួលសំណុំលិខិតបន្ទាប់<br>ពីការប្រឡងជាប់ | 〈រៀនពេលថ្ងៃ〉 ខែ 3ថ្ងៃទី1 (ចន្ទ័) 10:00～12:00<br>〈រៀនពេលយប់＊〉 ខែ 3ថ្ងៃទី1 (ចន្ទ័) 15:00～18:00<br>〈ប្រព័ន្ធប្រៃសណីយ៏〉 ខែ 3ថ្ងៃទី1 (ចន្ទ័) 10:00～12:00、13:00～15:00 | វិទ្យាល័យ<br>ដាក់ពាក្យប្រឡង |

＊ 県立横浜明朋高校(けんりつよこはまめいほうこうこう)、県立相模向陽館高校(けんりつさがみこうようかんこうこう)、横浜市立横浜総合高校(よこはましりつよこはまそうごうこうこう) 3 សាលារៀនពេលថ្ងៃខាងលើនេះប្រឡងពេលវេលាដូចគ្នា។

＊＊ក្នុងករណីកើតគ្រោះធម្មជាតិធំ ដែលនាំអោយប្រលងមិនបានគ្រប់មុខវិជ្ជាអាចមានការប្រលងបន្ថែមនៅថ្ងៃផ្សេង។សិស្សដែលត្រូវប្រលងបន្ថែមចាំបាច់ត្រូវទាក់ទងនាពេលព្រឹកនៃថ្ងៃប្រលងទៅវិទ្យាល័យដែលខ្លួនត្រូវទៅប្រលង។

★ អំពីការសុំប្តូរពាក្យប្រឡង

・ អាចសុំប្តូរពាក្យប្រឡងចូលសាលាវិទ្យាល័យបានតែ១ដងតែប៉ុណ្ណោះ។

・ ការសុំប្តូរពាក្យប្រឡងគឺត្រូវបំពេញសំណុំលិខិតដូចតទៅ។

① ជាដំបូងទៅយកសំណុំលិខិតប្រឡងចូលសាលាវិទ្យាល័យនិងបំពេញលិខិតទាំងនោះ។

（ប្រយ័ត្ន：ជួនកាលត្រូវធ្វើសំណុំលិខិតសាជាថ្មី។ សូមសួរបញ្ជាក់ពីការិយាល័យចុះឈ្មោះ។）

② យកសំណុំលិខិត ①នោះហើយ យកទៅដាក់ពាក្យប្រឡងចូលសាលាវិទ្យាល័យថ្មី

（ប្រយ័ត្ន：ជួនកាលបើមានការដាក់ពាក្យនោះច្រើនពេកសូមមកពេលក្រោយម្តងទៀតដោយយកលិខិតសម្ភាសន៏ដាក់ជាមួយ។）

ខ្លឹមសារនៃការត្រួតពិនិត្យក្នុងការជ្រើសរើស

| | |
|---|---|
| រៀនពេលថ្ងៃ | ①「ការប្រឡងចំណេះដឹង」（មានមុខវិទ្យា 5 មុខភាសាអង់គ្លេស-អក្សរសាស្ត្រ-គណិតវិទ្យា-រូបវិទ្យា និងសង្គមវិជ្ជា) ប៉ុន្តែសាលា Creative School※ដែលមិនចាំបាច់ ប្រឡងចំណេះដឹង។<br>② មានអនុវត្តន៏「ការសម្ភាសន៏」។<br>③ 「ការពិនិត្យលក្ខណពិសេស」តាមវិទ្យាល័យខ្លះ មានធ្វើការពិនិត្យបញ្ចេកវិជ្ជា និងពិនិត្យសកម្មភាពផ្ទាល់ខ្លួនជាដើម។<br>（បើមានការពិនិត្យលក្ខណពិសេស ការប្រឡងចំណេះដឹងអាចបន្ថយមុខវិជ្ជាត្រឹម 3 មុខ។ |
| រៀនពេលយប់ | ① 「ការប្រឡងចំណេះដឹង」（មាន 3 មុខវិជ្ជា3គឺភាសាអង់គ្លេស-អក្សរសាស្ត្រ-គណិតវិទ្យា)<br>② 「ការសម្ភាសន៍」។<br>③ 「ការពិនិត្យលក្ខណពិសេស」នៅតាមវិទ្យាលយ័ខ្លះតម្រូវអោយមានធ្វើការបង្ហាញចលនាជាក់ស្តែងព្រមទាំងតម្រូវអោយធ្វើការបញ្ចេញមតិផ្ទាល់ខ្លួនផងដែរ។ |
| ប្រព័ន្ធប្រែសណើយ៍ | ① 「ការសម្ភាសន៏」ឬ「ការតែងសេចក្តី」។ |

※ Creative Schoolមាន 5 សាលា県立田奈高校、県立釜利谷高校、県立横須賀南高校 普通科មុខវិជ្ជាទូទៅ、県立大井高校、県立大和東高校

សេចក្តីលម្អិតនៃការជ្រើសរើសក្នុងករណីពិសេស

| | |
|---|---|
| ករណីពិសេស<br>ជនបរទេសក្នុងខេត្ត | មានសាលារៀនពេលថ្ងៃចំនួន12សាលា និងពេលយប់ចំនួន 1 សាលា（☞ទំព័រទី 13)<br>①「ប្រឡងចំណេះដឹង」(៣មុខវិជ្ជា ភាសាអង់គ្លេស- អក្សរសាស្ត្រ-គណិតវិទ្យា）។<br>※ ការប្រឡងចំណេះដឹង គឺ មានជាភាសាជប៉ុនដោយភ្ជាប់អក្សររឺប៊ីលើអក្សរខាន់ជី។<br>②「ការសម្ភាសន៏」 |
| ករណីពិសេស<br>សិស្សត្រឡប់មកពីបរទេស | មានសាលារៀនពេលថ្ងៃចំនួន 8 សាលា（☞ទំព័រទី 13)<br>① 「ប្រឡងចំណេះដឹង」(៣មុខវិជ្ជា ភាសាអង់គ្លេស- អក្សរសាស្ត្រ-គណិតវិទ្យា）។<br>② 「ការតែងសេចក្តី」និង「ការសម្ភាសន៏」។<br>※ វិទ្យាលយ័រដ្ឋ 「យ៉ូកូហាម៉ាខុឺសៃកូកូខុឺសៃកាក់ខុឺសៃបាខារ៉ូលេអាខូស」 គឺមាន 「ពិនិត្យលក្ខណពិសេស」 |

ចំណាំ１）「សេចក្តីណែនាំនៃការដាក់ពាក្យ」（សៀវភៅជាភាសាជប៉ុនដែលក្រសួងអប់រំចេញផ្សាយ ដែលចែកតាមសាលារដ្ឋសំរាប់សិស្សឆ្នាំទី3 នៅខែ 7 (កក្កដា)ដែលមានសេចក្តីពីសៀវភៅ「ប្រឡងចំណេះដឹង」និងការ「ពិនិត្យលក្ខណពិសេស」ជាដើម។

ចំណាំ２） ចំពោះសិស្ស ដែលបានដាក់ពាក្យប្រឡងជ្រើសរើសជាទូទៅនិងវិទ្យាល័យឯកជនគឺ និងមិនអាចដាក់ពាក្យសុំចូលប្រឡងក្នុងករណីពិសេសនេះបានទៀតទេ។（☞ទំព័រទី 14)

※ បើទោះជាត្រូវបដិសេធដោយសាលាទាំងនោះក៏ដោយ។

ចំណាំ３） ប្រឡងសមត្ថភាពសិក្សាក្នុង១មុខវិជ្ជាគឺ៥០នាទី។ចង់បន្ថែមម៉ោងក្នុងករណីពិសេសត្រូវដាក់ពាក្យទុកជាមុន។（☞ P.15)
សាលារៀនពេលថ្ងៃនិងសាលារៀនពេលយប់ការប្រឡងចំណេះដឹងអាចមានសំណួរខុសពីគ្នា។

ចំណាំ４） ស្តីពីកម្រងសំណួរប្រឡងចំណេះដឹងសម្រាប់ឆ្នាំ2021សូមពិនិត្យមើលទៅលើគេហទំព័រខាងក្រោម
http://www.pref.kanagawa.jp/docs/dc4/nyusen/nyusen/kanagawa.html

របៀបជ្រើសយកនៃការជ្រើសរើសទូទៅ（របៀបសម្រេចឱ្យអ្នកប្រឡងជាប់）

①ទិន្នន័យនៃការជ្រើសរើស

មានសាលាខ្លះពិនិត្យលក្ខណៈ

| A　លទ្ធផលនៃសាលាអនុវិទ្យាល័យ（លិខិតសរុបពិន្ទុ） | B ពិន្ទុសរុបនៃការប្រឡងចំណេះដឹង | C ពិន្ទុនៃការសម្ភាសន៍ | D ពិន្ទុនៃការពិនិត្យលក្ខណៈ |
|---|---|---|---|
| អនុវិទ្យាល័យឆ្នាំទី 2 មានចែកពិន្ទុជា5 កំរិតសរុប（ពិន្ទុពេញមាន45ពិន្ទុ）<br>＋<br>អនុវិទ្យាល័យឆ្នាំទី 3 មានចែកពិន្ទុជា5 កំរិតសរុបគុណនិង 2（ពិន្ទុពេញមាន90ពិន្ទុ）<br>※មានសាលាខ្លះផ្តល់ពិន្ទុតាមមុខវិជ្ជាដែលកំណត់។ | ពិន្ទុសរុបនៃការប្រឡងចំណេះដឹង（គ្រប់មុខវិជ្ជា ពិន្ទុពេញមាន100ពិន្ទុ）<br>មានសាលាខ្លះផ្តល់ពិន្ទុតាមមុខវិជ្ជាដែលកំណត់។ | ពិន្ទុនៃការសម្ភាសន៍ | ពិន្ទុនៃការពិនិត្យលក្ខណៈ |

A B C（សាលាដែលពិនិត្យលក្ខណៈគឺបូកបញ្ចូលD ផងដែរ）ពិន្ទុនិមួយៗគឺសន្មតិថាពិន្ទុពេញមាន100ពិន្ទុ

| A លទ្ធផលនៃអនុវិទ្យាល័យ | Bពិន្ទុ សរុបនៃការប្រឡងចំណេះដឹង | C ពិន្ទុនៃការសម្ភាសន៍ | D ពិន្ទុនៃការពិនិត្យលក្ខណៈ |
|---|---|---|---|
| →a（ពិន្ទុពេញមាន100ពិន្ទុ） | →b（ពិន្ទុពេញមាន100ពិន្ទុ） | →c（ពិន្ទុពេញមាន100ពិន្ទុ） | →d（ពិន្ទុពេញមាន100ពិន្ទុ） |

សាលានីមួយៗកំណត់ចំនួនពិន្ទុតាមរបៀបពិន្ទុវិភាគ（f：g：h：i） a b c d（ទាមទារការពិនិត្យពិសេសណាមួយគឺ មិនបញ្ចូល i និង d ទេ）

ពិន្ទុវិភាគ（f：g：h：i）
ចំនួនគត់និមួយៗលើសពី២ឡើងទៅគឺស្មើនិង f និង g និង h ដែលសាលានីមួយៗកំណត់យកសរុបតម្រូវត្រឹម10។
ការអោយពិន្ទុ i គឺមានសាលាខ្លះកំណត់យកចំនួនគត់សរុបត្រឹម 5 ចុះក្រោម។

ចំនួនសរុបស្មើនិង $S = a \times f + b \times g + c \times h + d \times i$

ឧទាហរណ៍ នៃពិន្ទុវិភាគ（f：g：h：i）
　សាលាវិទ្យាល័យA គឺ យកលទ្ធផលនៃអនុវិទ្យាល័យជាមូលដ្ឋាន（6：2：2）គ្មានការពិនិត្យលក្ខណៈ
　សាលាវិទ្យាល័យB គឺ យកការប្រឡងចំណេះដឹងជាមូលដ្ឋាន（3：5：2）គ្មានការពិនិត្យលក្ខណៈ
　សាលាវិទ្យាល័យC គឺ យកការសម្ភាសន៍ពិនិត្យលក្ខណៈ（3：3：4：4）

※ពិន្ទុវិភាគនៅតាមសាលានីមួយៗនឹងឈ្មោះសាលាមានបោះផ្សាយនៅក្នុង「សេចក្តីណែនាំពីការប្រឡង」។

②របៀបសម្រេចពីការប្រឡងជាប់

ក្រោយពីបានត្រួតពិនិត្យរួចហើយ នៅតាមសាលានីមួយៗមាន បើកអង្គប្រជុំដើម្បីសម្រេចឱ្យជាប់កាប្រឡងដែលមានបើកការជ្រើសរើសវគ្គទី 1

វគ្គទី 2 ជាលំដាប់លំដោយទើបសម្រេចយក។

| | |
|---|---|
| ការជ្រើសរើសវគ្គទី 1 | **បេក្ខជនដែលមានពិន្ទុសរុបស្មើនិងSមានមធ្យមភាគ90%ត្រូវបានជ្រើសយក។** |
| ការជ្រើសរើសវគ្គទី 2 | លិខិតអង្កេតការ a គឺមិនត្រូវបានប្រើទេ គឺដកស្រង់សាជាថ្មីនៃចំនួនសរុប S រួមនិង b និង c（សាលាខ្លះដែលពិនិត្យលក្ខណៈគឺបូកបញ្ចូល d ផងដែរ）ដើម្បីសម្រេចនៃការជ្រើសរើស។<br>**※នៅពេលខ្លះgនឹងhនិងយកមកប្រើជាថ្មី** ជាថ្មីនោះគឺតម្រូវចំនួនគត់តាមសាលាកំណត់ឱ្យដោយនីមួយៗគិតពី 2 ឡើងទៅដោយសរុបចំនួនតម្រូវត្រឹម10។ |

※　សាលា「Creative School」គឺ（☞ទំព័រទី 11）និង 県立横浜明朋高校、県立相模向陽館高校

**គឺមិនប្រើលិខិតអង្កេតការដើម្បីធ្វើការសម្រេចនោះទេដោយបើកឱកាសសម្រាប់បេក្ខជនទាំងអស់។**

※　ចំណែកតាមប្រព័ន្ធប្រៃសណីយ៍វិញ គឺយកតាមលទ្ធផលលិខិតអង្កេតការសិក្សានឹងអង្កេតសមត្ថភាពដើម្បីជ្រើសរើសដោយបើកឱកាសសម្រាប់បេក្ខជនទាំងអស់។

※　អំពីមុខវិជ្ជាប្រឡង**ទាំង** អស់ទាំងសាលារៀនពេលថ្ងៃ រៀនពេលយប់ តាមប្រព័ន្ធប្រៃសណីយ៍ គឺការជ្រើសរើសត្រូវបានយោគយល់ចំពោះសិស្ស ដែលពុំអាចមានឯកសារឬមិនអាចបំពេញមួយចំនួន ដូចជាគ្មានលិខិត**អង្កេតការ**នៃការសម្រេចចេញ**អនុវិទ្យាល័យ**ជាដើម។

※　វិទ្យាល័យរបស់រដ្ឋឈ្មោះ「យ៉ូកូហាម៉ាខុឌឹសៃ」គឺមានបែបបទប្រលងផ្សេងគ្នារវាង①នឹង②ស្សូមពិនិត្យមើល「ការណែនាំក្នុងការជ្រើសរើស」

（２）សាលាចាប់ប្រកាសជ្រើសរើសពិសេសនៃជនបរទេសក្នុងខេត្តនិងសិស្សត្រូវបានត្រឡប់មកពីបរទេស

【 ករណីពិសេសនៃជនបរទេសក្នុងខេត្ត 】 រៀនពេលថ្ងៃ មាន 12សាលា ， រៀនពេលយប់មាន1សាលា

| ឈ្មោះវិទ្យាល័យ | ពេលសិក្សា | មុខវិជ្ជា | អាស័យដ្ឋាន | ចំនួនសិស្សដែលជ្រើសរើសឆ្នាំមុន ＊ |
|---|---|---|---|---|
| けんりつつるみそうごうこうこう<br>県立鶴見総合高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅរួម | よこはましつるみく<br>横浜市鶴見区 | 20 |
| けんりつよこはませいりょうこうこう<br>県立横浜清 陵 高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | よこはましみなみく<br>横浜市南区 | 13 |
| けんりつかわさきこうこう<br>県立川崎高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | かわさきしかわさきく<br>川崎市川崎区 | 12 |
| けんりつだいしこうこう<br>県立大師高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | かわさきしかわさきく<br>川崎市川崎区 | 10 |
| けんりつさがみはらやえいこうこう<br>県立相模原弥栄高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | さがみはらしちゅうおうく<br>相模原市中央区 | 10 |
| けんりつはしもとこうこう<br>県立橋本高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | さがみはらしみどりく<br>相模原市緑区 | 10 |
| けんりつやまとみなみこうこう<br>県立大和 南 高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | やまとし<br>大和市 | 10 |
| けんりついせはらこうこう<br>県立伊勢原高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | いせはらし<br>伊勢原市 | 10 |
| けんりつざまそうごうこうこう<br>県立座間総合高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅរួម | ざまし<br>座間市 | 10 |
| けんりつあいかわこうこう<br>県立愛川高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | あいこうぐんあいかわまち<br>愛甲郡愛川町 | 10 |
| けんりつさがみこうようかんこうこう<br>県立相模向陽館高校 | រៀនពេលយប់ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | ざまし<br>座間市 | ពេលព្រឹក 10<br>ពេលល្ងាច 10 |
| よこはましりつ そうごうこうこう<br>横浜市立みなと総合高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅរួម | よこはましなかく<br>横浜市中区 | 6 |
| よこはましりつよこはましょうぎょうこうこう<br>横浜市立横浜 商 業 高校 | រៀនពេលថ្ងៃ | ផ្នែកសិក្សាអន្តរជាតិ | よこはましみなみく<br>横浜市南区 | 4 |

◎ ក្នុងខេត្ត នៃវិទ្យាល័យ សាហ្គាមី យុកូកាំងសិស្ស អាចដាក់ពាក្យជាលើកទី២បានទៅតាមការកំណត់របស់សាលា។

【សាលាចាប់ជ្រើសរើសករណីពិសេសនៃសិស្សត្រលប់មកពីបរទេសរៀនពេលថ្ងៃមាន8សាលា

| ឈ្មោះវិទ្យាល័យ | ពេលសិក្សា | មុខវិជ្ជា | អាស័យដ្ឋាន | ចំនួនសិស្សដែលជ្រើសរើសឆ្នាំមុន ＊ |
|---|---|---|---|---|
| けんりつかながわそうごうこうこう<br>県立神奈川総合高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ<br>មុខវិជ្ជាទូទៅខាងវប្បធម៌អន្តរជាតិ | よこはましかながわく<br>横浜市神奈川区 | 10 |
| けんりつよこはまこくさいこうこう<br>県立横浜国際高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ ផ្នែកពតិមានអន្តរជាតិ | よこはましみなみく<br>横浜市南区 | 20 |
| | | បែបឯកតារបស់ខុឌីសែកាក់ខុឌីសែបាខារ៉ូលេអាខូស | | 5 |
| けんりつしんじょうこうこう<br>県立 新 城 高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | かわさきしなかはらく<br>川崎市中原区 | 10 |
| けんりつせいしょうこうこう<br>県 立 西 湘 高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | おだわらし<br>小田原市 | 10 |
| けんりつつるみねこうこう<br>県立鶴嶺高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | ちがさきし<br>茅ヶ崎市 | 15 |
| けんりつさがみはらやえいこうこう<br>県立相模原弥栄高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | さがみはらしちゅうおうく<br>相模原市中央区 | 5 |
| けんりついしだこうこう<br>県立伊志田高校 | រៀនពេលថ្ងៃ | មុខវិជ្ជាទូទៅ | いせはらし<br>伊勢原市 | 10 |
| よこはましりつひがしこうこう<br>横浜市立 東 高校 | រៀនពេលថ្ងៃ | ប្រព័ន្ធយកតាមពិន្ទុ មុខវិជ្ជាទូទៅ | よこはましつるみく<br>横浜市鶴見区 | 10 |

＊ នៅចុងខែ10ខាងមុខនេះនឹងមានចុះផ្សាយតាមសារពតិមានអំពីចំនួនសិស្សដែលត្រូវជ្រើសរើសអោយដាក់ពាក្យចូលរៀនក្នុងឆ្នាំ2021 នៅលើបណ្ដាញអ៊ីនថាណែតរបស់ក្រសួងអប់រំនៃខេត្តកាណាហ្គាវ៉ាផងដែរ។

（3） ការជ្រើសរើស 【សាលារៀនពេលយប់និង ប្រព័ន្ធប្រៃសណីយ៍】

※ អ្នកដែលប្រឡងជាប់ ការជ្រើសរើសទូទៅ ឬសាលាឯកជនហើយនោះ មិនអាចដាក់ពាក្យចូលបានទេ។

ការដាក់ពាក្យឬកម្មវិធីពិនិត្យ （អាចមានការប្រែប្រួលឬអាក់ខានទៅតាមស្ថានភាពរបស់មេរោគឆ្លងប្រភេទថ្មី 「កូរ៉ូណា」）

| ការដាក់ពាក្យនិងប្រឡង | ពេលវេលា | ទីកន្លែង |
|---|---|---|
| | | |
| ការដាក់ពាក្យប្រឡង | 〈រៀនពេលយប់〉 ខែ 3ថ្ងៃទី 3 (ពុធ) 14:00～19:00<br>ខែ 3ថ្ងៃទី 4 (ព្រហស្បតិ៍) 14:00～16:00<br>〈ប្រព័ន្ធប្រៃសណីយ៍〉 ខែ 3ថ្ងៃទី 3 (ពុធ) 9:00～12:00、13:00～17:00<br>ខែ 3ថ្ងៃទី 4 (ព្រហស្បតិ៍) 9:00～12:00、13:00～16:00 | វិទ្យាល័យ<br>ដាក់ពាក្យប្រឡង |
| រយៈពេលសុំប្តូរពាក្យប្រឡង | 〈រៀនពេលយប់〉 ខែ 3ថ្ងៃទី 5 (សុក្រ) 14:00～19:00<br>ខែ 3ថ្ងៃទី 8 (ចន្ទ) 9:00～12:00、13:00～16:00<br>〈ប្រព័ន្ធប្រៃសណីយ៍〉 ខែ 3ថ្ងៃទី 5 (សុក្រ) 9:00～12:00、13:00～19:00<br>ខែ 3ថ្ងៃទី 8 (ចន្ទ) 9:00～12:00、13:00～16:00 | មានបញ្ជាក់<br>ខាងក្រោម★ |
| ថ្ងៃប្រឡង | ប្រឡងចំណេះទូទៅ : ខែ**3** ថ្ងៃទី **１２** (សុក្រ)<br>សម្ភាសន៍・ពិនិត្យលក្ខណៈសម្បត្តិ : ខែ**3** ថ្ងៃទី **１２** (សុក្រ)・ ថ្ងៃទី **１５** (ចន្ទ)<br>※ពេលវេលាគឺមានសរសេរនៅលើក្រដាសប្រឡង | វិទ្យាល័យ<br>ដាក់ពាក្យប្រឡង |
| ប្រកាសលទ្ធផលប្រឡង<br>ទទួលសំណុំលិខិតបន្ទាប់<br>ពីការប្រឡងជាប់ | 〈រៀនពេលយប់〉 ខែ 3ថ្ងៃទី １ 9 (សុក្រ) 15:00～18:00<br>〈ប្រព័ន្ធប្រៃសណីយ៍〉 ខែ 3ថ្ងៃទី １ 9 (សុក្រ) 10:00～12:00、13:00～15:00 | វិទ្យាល័យ<br>ដាក់ពាក្យប្រឡង |

★ អំពីការសុំប្តូរពាក្យប្រឡង

・ អាចសុំប្តូរពាក្យប្រឡងចូលសាលាវិទ្យាលយ័បានគឺ 1 ដងតែប៉ុណ្ណោះ។

・ ការសុំប្តូរពាក្យប្រឡងគឺត្រូវបំពេញសំណុំលិខិតដូចតទៅ.

① ជាដំបូងទៅយកសំណុំលិខិតប្រឡងចូលពីសាលាវីទ្យាល័យនិងបំពេញលិខិតទាំងនោះ ។

(ចំណាំ : ពេលខ្លះត្រូវធ្វើសំណុំលិខិតសាជាថ្មី។ សូមសួរបញ្ជាក់ពីការិយាល័យចុះឈ្មោះ ។)

② យកសំណុំលិខិត①នោះហើយ យកទៅដាក់ពាក្យប្រឡងចូលសាលាវីទ្យាល័យថ្មី

(ចំណាំ : ពេលខ្លះបើមានការដាក់ពាក្យនោះច្រើនពេកសូមមកពេលក្រោយម្តងទៀតដោយយកលិខិតសម្ភាសន៍ដាក់ជាមួយផង ។)

ខ្លឹមសារលម្អិតនៃការប្រឡង

| | |
|---|---|
| រៀនពេលយប់ | ① 「ប្រឡងចំណេះដឹង」 （មានមុខវិជ្ជា3 ភាសាអង់គ្លេស-អក្សរសាស្ត្រ-គណិតវិទ្យា ក្នុង១មុខវិជ្ជា៣០នាទី）<br>② 「ការសម្ភាសន៍」<br>③ 「ការពិនិត្យលក្ខណពិសេស」<br>នៅតាមវិទ្យាលយ័ខ្លះតម្រូវអោយមានធ្វើការបង្ហាញចលនាជាក់ស្តែងព្រមទាំងតម្រូវអោយធ្វើការបញ្ចេញមតិផ្ទាល់ខ្លួនផងដែរ ។ |
| តាមប្រព័ន្ធប្រៃសណីយ៍ | ① 「ការតែងសេចក្តី」 និង 「ការសម្ភាសន៍」 |

របៀបជ្រើសរើស （របៀបសម្រេចយកអ្នកប្រឡងជាប់）

សាលារៀនពេលយប់ អ្នកចូលត្រូវប្រឡងទាំងអស់ ប្រឡងជ្រើសរើសទូទៅ តាមលំនាំដូច ការជ្រើសរើសវគ្គទី ១ （☞ទំព័រទ12） ។
ចំណែកតាមប្រព័ន្ធប្រៃសណីយ៍វិញ គឺយកតាមលទ្ធផលលិខិតអង្កេតការនិងលទ្ធផលប្រឡងដែលទទួលបានដើម្បីធ្វើសេចក្តីសម្រេច។

（４） ការប្រឡងជាលក្ខណៈពិសេសតាមការជ្រើសរើសទូទៅ

ការប្រឡងជាលក្ខណៈពិសេស អាចធ្វើបានតាមការជ្រើសរើសធម្មតា ដោយអាចដាក់ពាក្យប្រឡងនៅតាមវិទ្យាល័យរដ្ឋណាមួយក៏បានដែរ ។

【 សិស្សដែលអាចដាក់ពាក្យបាន 】

យោងតាមច្បាប់កំណត់ សិស្សដែលមកពីបរទេសបានមករស់នៅប្រទេសជប៉ុនអស់រយះពេល៦ឆ្នាំ (គិតមកដល់ថ្ងៃទី1ខែ2 ឆ្នាំ ２０２１)

【 របៀបដាក់ពាក្យប្រឡង 】

「ការដាក់ពាក្យប្រឡងសំរាប់សិស្សដែលមានអាណាព្យាបាលជាមកពីបរទេស」 ទាំងការប្រឡងទូទៅ

និងការប្រឡងដោយឡែក

សំណុំពាក្យមួយណាក៏ដោយចាំបាច់ត្រូវមានទម្រង់ស្នើសុំពិសេសសំរាប់អ្នកមានអាណាព្យាបាលមកពីបរទេស(តាមគំរោងលេខ5)។

ការដាក់ពាក្យនេះត្រូវមានហត្ថលេខាពីនាយកអនុវិទ្យាល័យ ដូច្នេះត្រូវពិភាក្សាជាមួយនឹងគ្រូទទួលខុសត្រូវប្រចាំថ្នាក់

អោយបានរួសរាន់ ។ ចំពោះសិស្សដែលពុំបានរៀននៅអនុវិទ្យាល័យត្រូវប្រញាប់ធ្វើការទាក់ទងទៅវិទ្យាល័យដែលខ្លួនចង់ចូលរៀន ។

【 ការស្នើសុំពិសេសពីរបៀបប្រឡង 】

① វិញ្ញាសារប្រឡងអាចស្នើសុំអក្សរជប៉ុនដោយដាក់ជាអក្សររូបុិ ហុីរ៉ាហ្កាណាពីលើអក្សរខាន់ជិ

② សុំពន្យាពេលម៉ោងប្រឡង( អាចពន្យាពេលបានយូរបំផុត1, 5ដង)

③ ពេលធ្វើសម្ភាសន៏សុំអោយប្រើពាក្យងាយស្រួលយល់និងនិយាយយឺត១

★ ហាមមិនអោយយកវចនានុក្រមចូល និងហាមយកអ្នកបកប្រែអោយមកអង្គុយជិត ។

★「ការប្រឡងសំរាប់សិស្សដែលមកពីបរទេស」ត្រូវយកតាមរបៀបប្រឡង①និង③「ការប្រឡងជាលក្ខណៈពិសេស」ណាមួយពុំត្រូវអនុញ្ញាតនោះទេ។
ក៏ប៉ុន្តែបើប្រឡងធ្លាក់ គឺអាចដាក់ពាក្យប្រឡង នៅ ការប្រឡងផ្សេងដោយឡែកមួយទៀតបើសិនជាទៅប្រឡងសូមប្រញាប់ដាក់ពាក្យឱ្យបានរួសរាន់ជាចាំបាច់ ។

★ សំរាប់សិស្សណាដែលមានពិបាកផ្នែករាងកាយក្នុងការទៅប្រឡង សូមពិភាក្សាជាមួយនឹងគណៈកម្មាធិការអប់រំខេត្ត ។

【 ទីកន្លែងទាក់ទង 】

ទីចាត់ការផ្នែកអប់រំជ្រើសរើសសិស្សចូលប្រឡង・កំណត់ជាក្រុម 高校教育課入学者選抜・定員グループ

ទូរស័ព្ទលេខ : 045-210-8084（ខ្សែផ្ទាល់-ជាភាសាជប៉ុន）

ចំណុចសំខាន់---- នៅពេលចូលរៀន

## 10. តំលៃនៃការសិក្សា

ដើម្បីចូលរៀនវិទ្យាល័យ ចាំបាច់ត្រូវបង់ថ្លៃសិក្សា។ ក្រៅពីនេះនៅមាន ថ្លៃប្រឡង និង ថ្លៃចូលរៀនថែមទៀតផង។

កម្មវិធីសាលារៀនពេលថ្ងៃ

| | |
|---|---|
| ថ្លៃចូលរៀន | ¥5, 650 |
| ថ្លៃសិក្សាក្នុង1ឆ្នាំ | ¥118, 800 |
| ចំពោះអ្នកដែលបានទទួលប្រាក់ជំនួយក្នុងការសិក្សា ※ | ¥0 |

កម្មវិធីសាលារៀនពេលយប់ (　)ក្នុងវង់ក្រចកជាតំលៃសាលាស្រុកយ៉ូកូហាម៉ា

| | |
|---|---|
| ថ្លៃចូលរៀន | ¥2, 100(¥1, 200) |
| ថ្លៃសិក្សាក្នុង1ឆ្នាំ | ¥32, 400 |
| ចំពោះអ្នកដែលបានទទួលប្រាក់ជំនួយក្នុងការសិក្សា ※ | ¥0 |

(តំលៃនៃការសិក្សាដែលបានបញ្ជាក់ដូចខាងលើនេះ គឺជាតំលៃនៅពេលបច្ចុប្បន្ន គឺនៅថ្ងៃទី 1ខែ5 ឆ្នាំ ２０２０នេះ។)

※ប្រាក់ជំនួយលើថ្លៃសិក្សាសាលាវិទ្យាល័យ (☞ទំព័រទី 17)

ថ្លៃវិទ្យាលយ័ ( ចំពោះសិស្សវិទ្យាល័យដែលបានទទួលប្រាក់ជំនួយក្នុងការសិក្សា )

| | | | |
|---|---|---|---|
| (ពិគ្រោះ) វិទ្យាល័យរដ្ឋ (រៀនពេលថ្ងៃ) | ប្រមាណ | ¥200, 000 | (ឆ្នាំដំបូង) |
| វិទ្យាល័យរដ្ឋ (រៀនពេលយប់) | ប្រមាណ | ¥ 40, 000 | (ឆ្នាំដំបូង) |
| វិទ្យាល័យឯកជន (រៀនពេលថ្ងៃ) | ប្រមាណ | ¥800, 000～ | (ឆ្នាំដំបូង) |

ចំនួនទឹកប្រាក់ដែលបានបញ្ជាក់ពីខាងលើគឺកម្រៃប្រាក់ដែលត្រូវបង់នៅពេលប្រឡងជាប់ហើយដាក់ពាក្យចូលរៀនក្នុង(ខែ3) ចំពោះអ្នករៀនពេលថ្ងៃធម្មតាត្រូវចំនាយប្រហែល10,0000យ៉េន(ថ្លៃសៀវភៅរៀន,ថ្លៃប្រដាប់ប្រដារៀន,សំលៀកបំពាក់សិស្ស សំលៀកបំពាក់កីឡា,ស្បែកជើងកីឡា។)ចំណែកវិទ្យាល័យឯកទេសនោះត្រូវចំណាយការរៀនបណ្តុះបណ្តាលផ្សេងៗទៀត។ ហើយថ្លៃធ្វើដំណើរទៅសាលា,ថ្លៃហាត់កីឡា,ថ្លៃសម្ភារសិក្សា,ថ្លៃខោអាវយ៉ូដូឬថ្លៃខោអាវហែលទឹក,នឹងថ្លៃប្រាក់សន្សំដើម្បីធ្វើដំណើរកំសាន្តនាពេលបញ្ចប់សិក្សា។

ចំពោះគ្រួសារដែលទទួលការថែទាំសុខុមាលភាពនិងមានប្រាក់ចំណូលនៃគ្រួសារតិចតួច(លើកលែងពន្ធ) គឺជា「សិស្សវិទ្យាល័យទទួលអាហារូបករណ៍」, ហើយក៏មានករណីលើកលែងដោយមិនចាំបាច់សងប្រាក់អាហារូបករណ៍នោះវិញទេ។ការជ្រើសរើសនឹងចាប់ផ្តើមពីខែកក្កដានៅសាលាវិទ្យាល័យនិមួយៗ។

ក្រៅពីនេះទៀត សាលាមានប្រព័ន្ធផ្តល់អាហាររូបករណ៍ដល់សិស្សដែល មានជីវភាពលំបាកផ្សេងៗ។ហើយអាហាររូបករណ៍គឺមាន២ករណីៈករណីមិនចាំបាច់សងត្រលប់វិញ ករណីចាំបាច់ត្រូវសងត្រលប់វិញ។អាហាររូបករណ៍និមួយៗគឺមានលក្ខខណ្ឌ។

## １１　ប្រាក់ជំនួយលើថ្លៃសិក្សាវិទ្យាល័យ

គោលបំណងនៃប្រាក់ជំនួយនេះគឺដើម្បីជួយកាត់បន្ថយការចំណាយការសិក្សារបស់សិស្សដោយពុំគិតពីស្ថានភាពជីវភាពគ្រួសារនោះទេ និងការផ្តល់ឱកាសសិក្សាដល់សិស្សដោយស្មើភាពគ្នា។

ប្រាក់ជំនួយពុំតម្រូវអោយសងមកវិញទេ។

ដើម្បីមានសិទ្ធអាចទទួលប្រាក់ជំនួយសិក្សាបាន,

សិស្សត្រូវដាក់ពាក្យសុំជាមុនសិន,សាលានឹងប្រគល់ក្រដាសដាក់ពាក្យសុំនិងពន្យល់បន្ថែមនៅពេលចូលសាលាដំបូង។

◎មានសៀវភៅណែនាំជាភាសាខ្មែរ។បើត្រូវការសូមពិគ្រោះជាមួយសាលាដែលត្រូវចូល។

＜លក្ខខណ្ឌក្នុងការផ្តល់ប្រាក់＞

○អាណាព្យាបាល (អ្នកមានសិទ្ធិជាឪពុកឬម្តាយបើមានទាំងសងខាងបូកបញ្ចូលទាំង២នាក់)

មានការបង់ពន្ធចំនួនក្រោម ３０４，２００ យ៉េន (ប្រាក់ចំណូលប្រចាំឆ្នាំក្រោម៩，１００,０００ យ៉េន)

[រូបមន្តគណនា] )(ចំនួនស្តង់ដារពន្ធរបស់ក្រុងឬស្រុក) x ６％ - (ការកាត់បន្ថយពន្ធរស់នៅក្រុងឬស្រុក)

○ គ្រួសារដែលទទួលការឧបត្ថមជីវភាពពីរដ្ឋ

＜ឯកសារដែលត្រូវដាក់＞

① លិខិតស្នើសុំ(នៅគ្រប់វិទ្យាល័យមាន ចែកជូន)

② ត្រូវថតចម្លងកាតអត្តលេខរបស់អាណាព្យាបាលទាំង២ (កាតអត្តលេខ, កាតជូនដំណឹងលេខ១២ខ្ទង់សម្គាល់បុគ្គល, ក្រដាសបញ្ជាក់ទីលំនៅដែលមានលេខ១២ខ្ទង់សម្គាល់បុគ្គលនឹងក្រដាសបញ្ជាក់បន្ថែមពីលើក្រដាសបញ្ជាក់ទីលំនៅនោះជាដើម)

＜លក្ខខណ្ឌដាក់ពាក្យ＞

តាមគោលការណ៍របស់សាលាគឺត្រូវបញ្ចូញក្រដាស់១ដង (វិទ្យាលយ័ដែលត្រូវចូលនឹងជូនដំណឹងអំពីកាលបរិច្ឆេទ)

【បន្តាញទំនាក់ទំនងស្តីពីប្រាក់ជំនួយលើថ្លៃវិទ្យាល័យ 】

・ការិយាល័យរបស់វិទ្យាល័យដែលបានចូលរៀន

・神奈川県教育委員会教育局財務課財務指導グループ (かながわけんきょういくいいんかいきょういくきょくざいむかざいむしどう)　ទូរស័ព្ទលេខ : 045-210-8113(ខ្សែផ្ទាល់ -ជាភាសាជប៉ុន )

## １２ ពត៌មានស្តីអំពីប្រពន្ធ័នៃប្រាក់ឧបត្ថម្ភលើថ្លៃសិក្សាសម្រាប់វិទ្យាលយ័ឯកជន

ដើម្បីកាត់បន្ថយលើការចំណាយរបស់អាណាព្យាបាលទៅលើថ្លៃសិក្សារបស់សិស្ស,ខេត្តកាណាហ្គាវ៉ាមានប្រពន្ធ័ឧបត្ថម្ភថ្លៃបែបបទដាក់ពាក្យចូលសាលានិងថ្លៃសិក្សាដោយមិនតម្រូវអោយសងត្រលប់មកវិញនោះទេ។

សូមបញ្ជាក់ថា៖សិស្សត្រូវបង់ថ្លៃបែបបទចូលសាលានឹងថ្លៃសិក្សាជាមុនសិន,បន្ទាប់ពីបានចូលសាលារួចរាល់ហើយសិស្សនឹងទទួលប្រាក់ឧបត្ថម្ភទាំងនោះតាមក្រោយ។

សម្រាប់ពត៌មានលម្អិតសូមទាក់ទងទៅវិទ្យាលយ័ឯកជននីមួយៗដែលសិស្សចង់ដាក់ពាក្យចូលរៀន។

**(ឧទាហរណ៍ក្នុងការគណនា)**ក្នុងករណីប្រាក់ចំណូលសរុបប្រចាំឆ្នាំរបស់សមាជិកគ្រួសាររបស់សិស្សមានចំនួនក្រោម700មុឺនយ៉េនឬជាគ្រួសារដែលទទួលការឧបត្ថម្ភជីវភាពពីរដ្ឋ,សិស្សនឹងអាចទទួលបានប្រាក់ឧបត្ថម្ភថ្លៃសិក្សា¥444,000

ក្នុងករណីប្រាក់ចំណូលសរុបប្រចាំឆ្នាំរបស់សមាជិកគ្រួសាររបស់សិស្សមានចំនួនក្រោម750មុឺនយ៉េន,សិស្សនឹងអាចទទួលបានប្រាក់ឧបត្ថម្ភថ្លៃសិក្សា¥193,200

ក្នុងករណីប្រាក់ចំណូលសរុបប្រចាំឆ្នាំរបស់សមាជិកគ្រួសាររបស់សិស្សមានចំនួនក្រោម៩10មុឺនយ៉េន,សិស្សនឹងអាចទទួលបានប្រាក់ឧបត្ថម្ភថ្លៃសិក្សា¥118,800

ចំនួនទឹកប្រាក់ឧបត្ថម្ភថ្លៃសិក្សាដូចដែលបានគណនាខាងលើនេះគឺសម្រាប់សិស្សដែលមានទីលំនៅក្នុងខេត្តកាណាហ្គាវ៉ា។

ចំនួនទឹកប្រាក់ឧបត្ថម្ភគឺសម្រេចទៅតាមរយៈការបង់ពន្ធរបស់អាណាព្យាបាលទាំងពីរ(អ្នកមានសិទ្ធិជាអាណាព្យាបាល)ដោយមានការពិនិត្យមើលទៅលើប្រាក់ចំណូលហើយផ្តល់ទឹកប្រាក់គិតតាមស្តង់ដារគោល ។

សម្រាប់ពត៌មានលម្អិតសូមពិនិត្យមើល「ការណែនាំក្នុងការដាក់ពាក្យ」

**【លេខទូរសព្ទ័ទំនាក់ទំនងអំពីប្រពន្ធ័ប្រាក់ឧបត្ថម្ភថ្លៃសិក្សាសម្រាប់វិទ្យាលយ័ឯកជន】**

・県子どもみらい部私学振興課助成グループ　TEL (045)210-3793 [លេខទូរសព្ទ័ខ្សែផ្ទាល់ ・ ពិគ្រោះជាភាសាជប៉ុន]

## １３.ការចូលរៀនវិទ្យាល័យសាជាថ្មីម្តងទៀត

① ការចូលរៀននៅវិទ្យាល័យសាជាថ្មីម្តងទៀត

ក្រោយពេលដែលបានចូលរៀននៅវិទ្យាល័យបានលើសពីមួយឆ្នាំហើយ ក៏ឈប់រៀនវិញ ប៉ុន្តែក្រោយមកក៏ចង់ចូលរៀនសាជាថ្មីម្តងទៀត នេះគេហៅថាការចូលរៀននៅវិទ្យាល័យសាជាថ្មីម្តងទៀត។

សិស្សដែលបានរៀននៅវិទ្យាល័យឯបរទេស ហើយបានមកចូលរៀននៅវិទ្យាល័យប្រទេសជប៉ុន ចំពោះករណីនេះ ក៏គេហៅថាការចូលរៀននៅវិទ្យាល័យសារជាថ្មីម្តងទៀតដែរ។

សិស្សានុសិស្សអាចដាក់ពាក្យប្រឡងចូលនៅតាមវិទ្យាល័យដែលបានជ្រើសរើស(ការសម្ភាសន៍ ការប្រឡងផ្នែកចំណេះដឹង) ហើយបើប្រឡងជាប់សិស្សនោះអាចចូលរៀននៅវិទ្យាល័យសាជាថ្មីម្តងទៀតបាន។

★ ដើម្បីចូលវិទ្យាល័យរដ្ឋនៅក្នុងខេត្តកាណាហ្គាវ៉ា(ប្រព័ន្ធរៀនពេលថ្ងៃ)សិស្សានុសិស្សនិងអ្នកអាណាព្យាបាលត្រូវមានអាស័យដ្ឋានក្នុងខេត្តកាណាហ្គាវ៉ាជាចាំបាច់។

② ការចូលរៀននៅវិទ្យាល័យសារជាថ្មីឡើងវិញសំរាប់អ្នកដែលមកពីបរទេស

ចំពោះសិស្សដែលចង់ចូលរៀន ត្រូវបញ្ចប់ ឬទទួលការសិក្សានៅឯបរទេសលើសពីរយះពេល 10ឆ្នាំ ឡើងទៅ។

រយះពេលដែលសិស្សានុសិស្សអាចដាក់ពាក្យចូលរៀនសាជាថ្មីបាន គឺកំណត់នៅថ្ងៃទី 1ខែ4 ដោយមានការសាកល្បងពីកិរិតវិជ្ជា និងការធ្វើសម្ភាសន៍ថែមទៀតផងក្នុងខែ ３។

ក្នុងករណីសាលានីមួយៗនៅមានចំនួនសិស្សមិនគ្រប់គ្រាន់ សិស្សអាចដាក់ពាក្យចូលរៀនសាជាថ្មីបាន។

ការជ្រើសរើស ជាពិសេសសំរាប់ជនបរទេសទាំងនោះអាចធ្វើទៅបាន បើសិស្សនោះបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់។ (ដាក់ពាក្យប្រឡង☞ ទំព័រទី５)

ក្រោយពេលដែលបានប្រឡងជាប់ កំរិតថ្នាក់ដែលអាចរៀនបាន ត្រូវកំណត់ដោយនាយកវិទ្យាល័យ ដែលត្រូវចូលរៀននោះ។

**[បណ្តាញទំនាក់ទំនង]**

神奈川県教育委員会の転編入学情報センター (かながわけんきょういくいいんかい てんぺんにゅうがくじょうほう)

ក្រុមប្រឹក្សាភិបាលអប់រំប្រចាំខេត្តកាណាហ្គាវ៉ា មជ្ឈមណ្ឌលផ្តល់ពតិមានពីការផ្លាស់ប្តូរសាលារៀន

ទីតាំង 横浜市中区日本大通３３ 神奈川県住宅供給公社ビル６階 (よこはましなかくにほんおおどおり かながわけんじゅうたくきょうきゅうこうしゃ かい) (មើលតាមផែនទីខាងក្រោម)

លេខទូរស័ព្ទ : 045-210-8235(ខ្សែផ្ទាល់-ជាភាសាជប៉ុន) ពីថ្ងៃច័ន្ទ～ថ្ងៃសុក្រ ពីម៉ោង 8:30～12:00 ・ 13:00～17:15

មានករណីផ្លាស់ប្តូរទីតាំងនឹងប្តូរលេខទូរសព្ទ័នៅក្នុងឆ្នាំនេះ។សូមពិនិត្យមើលគេហទំព័រទុកជាមុន។



## １４．សំណួរទូទៅ

ចំលើយនៃសំណួរគឺ : មើលទៅទំព័រដែលបានដាក់សញ្ញា☞

１．តើអ្វីជា(កូតាវិទ្យាលយ័ខេត្ត)(ការជ្រើសរើសពិសេសចំពោះជនបរទេសរស់នៅក្នុងខេត្ត)។តើមានវិទ្យាល័យណាខ្លះទៅ?

☞　P.5、P.6、P.13

２．ពេលប្រលងចូលវិទ្យាល័យ　តើប្រលងមុខវិជ្ជាអ្វីខ្លះ?ដូចជា(ពិនិត្យលទ្ធផលនៃការសិក្សា)។ពេលសំភាសន៍តើត្រូវសួរសំណួរអ្វីខ្លះ?

☞　P.8、 P.11

３．អ្វីទៅដែលហៅថា(ការអង្កេតការ)　?

☞　P.7　ទំព័រទី៧(ចំពោះសិស្សដែលបានបញ្ចប់អនុវិទ្យាល័យនៅបរទេសមិនត្រូវការអង្កេតការ ទេ)។

４．បច្ចុប្បន្ននេះចង់ប្រលងចូលវិទ្យាល័យ、តើត្រូវប្រលងនៅពេលណា?ហើយត្រូវការឯកសារអ្វីខ្លះ?

☞　P.3、P.4、P.9

５．ដោយពុំមានទំនុកចិត្តខ្លួនឯងជាភាសាជប៉ុន、តើមានការលើកលែងណាមួយពីការប្រឡងឬសម្ភាសន៍ទេ?

☞　P.11、P.15

６．សម្រាប់បេក្ខជនបញ្ចប់ការសិក្សាមកពីអនុវិទ្យាលយ័នៅបរទេស ដើម្បីប្រលងចូលវិទ្យាល័យនៅក្នុងខេត្តកាណាហ្គាវ៉ា
តើត្រូវការចាំបាច់សំណុំឯកសារ អ្វីខ្លះ?　☞　P.6、P.9

７．ធ្លាប់ចូលរៀនវិទ្យាល័យនៅប្រទេសក្រៅពីប្រទេសជប៉ុន។　តើអាចចូលរៀនវិទ្យាល័យនៅក្នុងខេត្តកាណាហ្គាវ៉ាចាប់ពីឆ្នាំទី២និងទី៣បានទេ?

☞　P.18

８．បន្ទាប់ពីប្រលងជាប់ចូលវិទ្យាល័យ、តើអាចដាក់ពាក្យប្រលងចូលវិទ្យាល័យផ្សេងទៀតបានឬទេ?

☞　P.11

９．បន្ទាប់ពីប្រលងជាប់វិទ្យាល័យ、តើត្រូវការបង់ប្រាក់ប៉ុន្មាន?　☞　P.16、P.17

សំណួរបន្ទាប់គឺ、ចំលើយម្នាក់ៗខុសៗគ្នា、ដើម្បីទទួលពត៌មានលំអិតសូមទំនាក់ទំនងទៅក្រុមប្រឹក្សាភិបាលអប់រំប្រចាំខេត្តកាណាហ្គាវ៉ា

１０．តើត្រូវធ្វើការជ្រើសរើសវិទ្យាលយ័ដែលត្រូវប្រលងចូលយ៉ាងដូចម្តេច?

☞　ចុះទៅទស្សនាផ្ទាល់តើវិទ្យាល័យណាមួយដែលសមរម្យចំពោះខ្លួនយើង, រួចធ្វើការសំរេចចិត្ត។

１１．តើខ្លួនមានលក្ខណៈគ្រប់គ្រាន់សំរាប់ការជ្រើសរើសអោយចូលរៀនតាមបែបពិសេសឬតាមបែបមកពីបរទេស？

☞　អាចត្រួតពិនិត្យតាមរយៈលិខិតឆ្លងដែន（☞P.6)

１２．ដើម្បីប្រលងជាប់ចូលរៀនវិទ្យាល័យ、តើត្រូវការយកពិន្ទុប៉ុន្មានដែរ?

☞「○○ពិន្ទុប៉ុន្មានអាចប្រលងជាប់」

ការកំណត់របស់សាលានីមួយៗមិនមានតួលេខច្បាស់លាស់ទេ។សម្រេចទៅលើលំដាប់ពិន្ទុសិស្សដែលចូលរួមប្រឡង។

１３．បើសិនករណីប្រលងមិនជាប់、តើត្រូវធ្វើរបៀបណា?

☞　ឱកាសប្រលងមានច្រើនទៀត、សូមអាននៅទំព័រទី៣

１４．　ភាសាជប៉ុនមិនទាន់គ្រប់គ្រាន់តើអាចមានបញ្ហាក្នុងការសិក្សាទេ？

☞　វិទ្យាលយ័ខ្លះមានបង្រៀនភាសាជប៉ុនឬបង្រៀនជាលក្ខណៈដោយឡែកទៅតាមកម្រិតរបស់សិស្សម្នាក់ៗ។

「日本語を母語としない人たちのための高校進学ガイダンス」

# 今年度は実施しません。

「សៀវភៅពន្យល់ណែនាំអំពីការប្រឡងចូលវិទ្យាល័យសំរាប់សិស្សដែលភាសាជប៉ុនមិនមែនជាភាសាកំណើត」

**ឆ្នាំនេះមិនមានបើកកម្មវិធីពន្យល់ទេ**

神奈川県の公立高校入学者選抜の多言語情報を

次のホームページで提供します。

។ដើម្បីទទួលពត៌មានជាភាសាផ្សេងៗស្ដីពីការជ្រើសរើសសិស្សចូលរៀននៅវិទ្យាលយ័រដ្ឋក្នុងខេត្តកាណាហ្កាវ៉ា សូមពិនិត្យមើលនៅលើគេហទំពរ័ គេហទំព័រនេះនឹងបើកនៅខែកញ្ញា។

http://me-net.or.jp/guidance/

ホームページは9月にオープンします。

គេហទំព័រនេះនឹងបើកនៅខែកញ្ញា។

